មជ្ឈមណ្ឌលឯកសារកម្ពុជា

## ស្រី ពុជ ហៅ ឈឿត ក០០៨៧៦ (ចាប់ខ្លួន)

## ជួបសម្ភាសជាមួយពូ ស្រី ស៊ីន អាយុ៥៤ឆ្នាំ ត្រូវជាបងប្រុស
## រស់នៅក្នុងភូមិកន្ទឺ ឃុំកន្ទឺ ស្រុកបាណន់ ខេត្តបាត់ដំបង
## ធ្វើនៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៦
## សម្ភាសដោយៈ ស៊ិរិ សាវីណា

វីណាៈ ពូពួកខ្ញុំមកពីមជ្ឈមណ្ឌលឯកសារកម្ពុជាណាពូ ដែលជាកន្លែងចងក្រងឯកសារពីប្រវត្តសម័យបីឆ្នាំ ហើយពួកខ្ញុំមកនេះគឺតាមរយៈប្រវត្តិរូបរបស់ប្អូនពូឈ្មោះ ស្រី ពុជ ហ្នឹងណាដែលបានមករកឃើញនៅក្នុងភូមិហ្នឹង ហើយព្រឹកមិញខ្ញុំបានសម្ភាសជាមួយម្ដាយរបស់ពូ ហើយឥឡូវនេះគឺខ្ញុំចង់សម្ភាសជាមួយពូបញ្ជាក់បន្ថែមពីរឿងរបស់គាត់ថែមទៀតណា ហើយពូមានឆ្ងល់អីពីពួកខ្ញុំដែលទេ?

ស៊ីនៈ ទេ! អត់មានឆ្ងល់អីទេ។

វីណាៈ ហើយព័តមានអស់ហ្នឹង តើខ្ញុំអាចយកទៅសរសេរចុះផ្សាយនៅក្នុងទស្សនាវដ្ដី ឬក៏ចងក្រងទុកឲ្យក្មេងជំនាន់ក្រោយ តើពូអត់មានថាអីទេ?

ស៊ីនៈ អត់ថាអីទេ អាហ្នឹងវាចារទុកជាប្រវត្តិសាស្រ្តទុកឲ្យក្មេងនៅសម័យក្រោយវាដឹងណា អាហ្នឹងគឺខ្ញុំឯកភាពដែរ ពីព្រោះវាបានអានេះទុកជាឯកសារទុកឲ្យក្មេងៗជំនាន់ក្រោយឲ្យវាឃើញ ឲ្យវាដឹងថារបបនេះវាយ៉ាងម៉េច របបនោះវាយ៉ាងម៉េច ពីព្រោះក្មេងៗនិយាយប្រាប់វាអីគឺអត់ជឿទេ។

វីណាៈ អញ្ចឹងដំបូងគឺខ្ញុំចង់ស្គាល់ឈ្មោះពូសិន តើពូមានឈ្មោះអីដែរ?

ស៊ីនៈ ខ្ញុំឈ្មោះ ស្រី ស៊ីន។

វីណា៖	ពូមានអាយុប៉ុន្មានហើយ?

ស៊ីន៖	ខ្ញុំអាយុ៥៤ហើយ ។

វីណា៖	ស្រុកកំណើតពូនៅឯណាដែរ?

ស៊ីន៖	នៅនេះឯង ស្រុកកំណើតនៅនេះឯងគ្មានទៅណាមកណាអីទេ ។

វីណា៖	ស្រុកកំណើតនៅនេហ្នឹង ភូមិអីឃុំអីដែរ?

ស៊ីន៖	ភូមិកន្ទីពីដើមណាក្មួយ តែឥឡូវនេះគេហៅថាភូមិវត្តកន្ទី ។

វីណា៖	ឃុំអីគេដែរពូ?

ស៊ីន៖	ពីដើមគេហៅថាភូមិកន្ទី តែមកឥឡូវនេះគេហៅថាភូមិកន្ទី១ ខុសគ្នាតិចៗ ។

វីណា៖	ចុះស្រុក?

ស៊ីន៖	ពីមុនស្រុកបាណន់ តែមកឥឡូវស្រុកសង្កែ ។

វីណា៖	ចុះម៉េចបានជាគេបែកចែកឃុំកន្ទី១ កន្ទី២អញ្ចឹង?

ស៊ីន៖	ពីព្រោះកន្ទីហ្នឹងគឺវាធំពេក វាឈ្មោះហ្នឹងវាធំពេក ដល់តែគេរៀបចំទៅគឺគេចែកជាភូមិ ដល់អញ្ចឹងជាភូមិគឺជាពីរ ដល់ជាភូមិអញ្ចឹងគឺគេគិតថាជាភូមិកន្ទី១-កន្ទី២ ពីដើមបើគេដាក់តែមួយទៅគឺវាច្រើនពេកណា អញ្ចឹងគេដាក់ជាពីរភូមិអញ្ចឹងទៅ ក៏កើតជាកន្ទី១-កន្ទី២ទៅ ។

វីណា៖	ចុះពូមានបងប្អូនប៉ុន្មាននាក់ពូ?

ស៊ីន៖	ខ្ញុំមានច្រើនណាស់ក្មួយ បើគិតទៅគឺជាង១០នាក់ណោះ ។

វីណា៖	ប៉ុន្មានដណ្តប់ទៅ?

ស៊ីន៖	១២នាក់ ។

វីណា៖	១២នាក់ហ្នឹងនៅរស់ទាំងអស់?

ស៊ីន៖	១២នាក់ហ្នឹងគឺស្លាប់អស់៤នាក់ ។

វីណា៖	៤នាក់ហ្នឹងប្រុសឬក៏ជាស្រី?

ស៊ីន៖	៤នាក់ហ្នឹងគឺសុទ្ធតែជាប្រុសដែលស្លាប់ហ្នឹង ។

វីណា: ម្នាក់គឺមានស្រី ពុជ ហ្នឹងហើយចុះអ្នកផ្សេងទៀត តើអ្នកណាគេខ្លះទៅ?

ស៊ីនៈ គឺប្រុសដែរ ។

វីណា: ឈ្មោះអីខ្លះទៅ?

ស៊ីនៈ អាហ្នឹងគឺដាក់ត្រកូលដូចគ្នា គឺមានឈ្មោះ ស្រី ហាន់ . ស្រី ហៀក . ហើយហ្នឹងម្នាក់ទៀតឈ្មោះ ស្រី ស៊ុំ ។

វីណា: គាត់ស្លាប់ដោយសារអីដែរ?

ស៊ីនៈ បើបងខ្ញុំម្នាក់នោះឈ្មោះស្រីស៊ុំនោះ គឺគាត់ស្លាប់នៅសម័យយើងនៅជំនាន់ លន់ នល់ ទេណា ព្រោះគាត់ធ្វើជាទាហាននៅសម័យ លន់ នល់ គាត់ទៅកាន់ទាហាននៅឈើខ្មៅណោះ ខេត្តតាកែវនោះណា ហើយគាត់ត្រូវគ្រាប់ដែលខ្មែរក្រហមវាផ្លោងដាក់មកត្រូវឃ្លាំងរបស់គាត់ គាត់កាន់កាំភ្លើងធំ ដល់អញ្ចឹងគាត់ស្លាប់ទៅ ។

វីណា: ឆ្នាំណាដែរ?

ស៊ីនៈ គាំងពីឆ្នាំ៧៣គាមមើល ។

វីណា: ហើយចុះប្អូនបន្ទាប់?

ស៊ីនៈ ប្អូនខ្ញុំបន្ទាប់មកឈ្មោះ ស្រី ពុជ នេះគឺស្លាប់នៅក្នុងសម័យបីឆ្នាំ ហើយក្រោយមកទៀតមានមួយទៀត អាហ្នឹងគឺស្លាប់ដោយសារតែខ្មែរក្រហមគេចាប់ដែរ វាធ្វើជាទាហាននៅសម័យយើងរដ្ឋកម្ពុជានេះណា សម័យយើងរំដោះនៅឆ្នាំ៧៩នេះណា សម័យយើងធ្វើជាទាហានជាមួយវៀតណាមនេះណា កាលហ្នឹងយើងមានទ័ពយើងឈ្មោះថារណសិរ្សសាមគ្គីសង្គ្រោះជាតិនោះ គឺរួមជាមួយហ្នឹងវៀតណាម ហើយវាទៅធ្វើជាទ័ពជាមួយហ្នឹង វៀតណាមនេះឯង ទៅច្បាំងអញ្ចឹងទៅ ហើយដល់ពេលដែលវាមកវិញវាទៅកាប់អំពៅ
ដល់ទៅកាប់អំពៅ វាចំហ្នឹងខ្មែរក្រហមដែលវានៅក្នុងចំការអំពៅណា
ដល់អញ្ចឹងវាចាប់ សម្លាប់ទៅ នៅផ្លូវយើងបែងមានជ័យនេះ ។

វីណា៖ អញ្ចឹងបានន័យថានៅពេលដែលបែក៧៩ហើយក្លាមៗហ្នឹង នៅតំបន់ពូនេះគឺនៅមានខ្មែរ ក្រហមនៅឡើយ?

ស៊ីន៖ នៅមានខ្មែរក្រហមនៅមាននៅឡើយ ប៉ុនវៀតណាមយើងនៅមានតែវានៅមានលាក់ខ្លួន នៅតានព្រៃនៅឡើយ ដល់ពេលដែលយើងទៅជួបវាទៅគឺវាចាប់យើងទៅ ។

វីណា៖ ចុះឥឡូវនៅមានទៀតដែលអត់?

ស៊ីន៖ ឥឡូវអត់មានទេ ។

វីណា៖ ចុះដល់ពេលណាដែលគេចុះចូលអីអស់ទៅ?

ស៊ីន៖ ទើបតែមកយើងនៅឆ្នាំ៩៣នេះ ដែលយើងគ្រាន់បានសុខស្រួលគ្រាន់ណា ដូចថាគេចុះចូលជាមួយយើង ចាប់ពី៩៣-៩៧មកបានធូរស្រាល បើនៅក្នុងចន្លោះហ្នឹងទៅក្រោយ អញ្ចេះគឺមានការលំបាកណាស់ក្មួយអើយ ។

វីណា៖ មានគ្រាប់ខ្មែរក្រហមដែរ?

ស៊ីន៖ ខ្មែរក្រហមគេអាសារចេញចូល គេលួចមកសម្លាប់យើងចាប់យើងណា ហើយដូចជាខ្ញុំនេះធ្វើការជាមេភូមិអី គឺរស់ទាំងវេទនាសូម្បីតែប្រពន្ធកូនអីមិនដែលបានរស់នៅជាមួយ គ្នាទេ គឺយកទៅទុកនៅក្រោមៗណោះ គឺខ្ញុំរស់នៅតែឯងទេ ពីព្រោះយប់ឡើងវាចូលមកហើយវារកយើងដែលជាអ្នកធ្វើការអញ្ចឹង ដូចជាយើងធ្វើជាមេភូមិអញ្ចឹងគឺវាចាប់យើងយកទៅសម្លាប់ ឲ្យតែចាប់បាននៅសម័យនោះគឺវាដឹងតែសម្លាប់តែហ្មង ។

វីណា៖ ចុះពូធ្វើជាអីនៅកាលនោះ?

ស៊ីន៖ ខ្ញុំធ្វើជាមេភូមិរហូតមកដល់ឥឡូវនេះ បើគិតទៅគឺតាំងពីឆ្នាំ៧៩មក ។

វីណា៖ ចុះប្អូនពូមួយទៀតនោះស្លាប់ដោយសារអីដែរ?

ស៊ីន៖ មួយទៀតនោះស្លាប់ដោយសារឈឺទេ ។

វីណា: ចុះពូចង់សួរត្រឡប់ទៅប្អូនពូបន្ទាប់ពូនេះវិញណា ខ្ញុំចង់ដឹងនៅពេលថានៅដឹបូនឡើងតើ គាត់នៅធ្វើអីបានជាគាត់ចូលទៅបក្សដិវត្តន៍ហ្នឹង?

ស៊ីន: កាលហ្នឹងនៅក្នុងសម័យ លន់ នល់ គឺស្រុកវាកើតសង្គ្រាមហើយណា គឺនៅក្នុងឆ្នាំ១៩៧០ហ្នឹងគឺប្អូនខ្ញុំវាទៅតាមគេណា គឺវាមានគ្នានោះវានៅកំលោះណាអាយុទើបតែ ១៧-១៨ឆ្នាំ ដល់វាមានគ្នាអញ្ចឹងគឺវានាំគ្នាទៅមើលកុនគេនៅស្នឹងណោះ ដល់ពេលនោះខ្មែរក្រហមវាមកវៃ មកវៃអាកន្លែងដែលគេដាក់បញ្ចាំងកុនបញ្ចាំងអីហ្នឹងណា កន្លែងប្រជុំ ជនហ្នឹង ដល់តែវៃទៅគឺវាគៀរយកទៅ បើនិយាយទៅគឺវាគៀរដោយយកទៅណា ។

វីណា: អញ្ចឹងប្អូនពូគាត់មិនបានទៅដោយខ្លួនគាត់ទេ?

ស៊ីន: មិនមែនទៅដោយខ្លួនឯងទេ គឺពេលដែលវាទៅមើលទៅគឺគេគៀរយកទៅបណ្តោយទៅ ហើយអាប្អូនខ្ញុំហ្នឹងគឺវាដោយទៅតាមគេទេ ពីព្រោះនៅពេលដែលគេវៃហ្នឹងគឺគេគៀរយក ប្រជាជនយកទៅ គឺគេយកទៅកន្លែងគេទៅ ដល់អញ្ចឹងទៅគឺវាដោយទៅតាមគេទៅ ។

វីណា: គេយកទៅកន្លែងណា?

ស៊ីន: អូរ! ឆ្ងាយណាស់ បើយើងនិយាយទៅប្រាប់កន្លែងក៏មិនស្គាល់ដែរ នៅលើវៃចាបទៅទៀតណោះ បើនិយាយទៅនៅជិតជាយដែនណោះ គឺគេយកទៅដាក់នៅព្រៃនៅស្រុក លើនោះណា គឺវាយកទៅបង្កើតទ័ពវាទៀតនោះ ទាំងស្រីទាំងប្រុសកាលហ្នឹងដែលវាគៀរ យកទៅណាប្អូន ដែលវាចូលវៃប្រឹបៗ វៃទាហានយើងនៅសម័យ លន់ នល់ នោះ ដល់ពេលដែល លន់ នល់ រត់ទៅគឺវាគៀរបានប៉ុណ្ណាគឺវាគៀរយកទៅ ក្មេងស្រីក៏ដោយ

ប្រុសក៏ដោយគឺវាគៀរយកទៅទាំងអស់

បើនិយាយទៅគឺវាប្រមូលយកទៅកែនធ្វើជាទ័ព នោះណា

យកទៅបំពាក់រឿននយោបាយអីទៅ ហើយវាបំពាក់អាវុធឲ្យមកច្បាំងយើង វិញ ។

វីណាៈ អាហ្នឹងនៅក្នុងឆ្នាំណាដែរពូ?

ស៊ីនៈ ឆ្នាំ៧០ ៧១-៧២ហ្នឹង ។

វីណាៈ នៅពេលដែល លន់ នល់ គាត់ឡើងបានមួយឆ្នាំអីហ្នឹងអញ្ចឹង?

ស៊ីនៈ មួយឆ្នាំពីរឆ្នាំអីដែរ ។

វីណាៈ អញ្ចឹងបានន័យថាខ្មែរក្រហមហ្នឹងកើតមាននៅមុនហ្នឹងទៀត?

ស៊ីនៈ បើនិយាយពីរឿងដែលកើតសង្គ្រាមគឺវាមានកើតនៅមុនហ្នឹងទៀត ប្រហែលជានៅឆ្នាំ ៦៧-៦៨ណោះ កាលហ្នឹងសម្តេចអីប្រមូលទ័ពប្រចាំទឹកប្រចាំដីអីហ្នឹងណា ដល់តែវាមក ពេញមុខនៅក្នុងឆ្នាំ១៩៧០សម័យ លន់ នល់ នេះឯងអញ្ចឹងបានជាមានឃើញទ័ព ឃើញអីចេញមក ទ័ពគេដែលនៅខាងព្រៃហ្នឹងណា ដូចថាទ័ពគេអី៨-១០នាក់អីគឺគេ មានកាំភ្លើងអីមួយដើមអញ្ចឹងទៅ កាលហ្នឹងអត់ទាន់មានអាវុធអីធំដុំទេ គឺមានតែកាំភ្លើង ព្រៃអីណា គឺនៅក្នុងឆ្នាំ១៩៧០គឺមានឃើញអញ្ចឹង ឃើញគេដើរចុះមកនៅតាមភូមិ អញ្ចឹង គេមកបំផុសបំផុលអារឿននយោបាយណា គឺគ្នា១០នាក់មានកាំភ្លើងមួយ ដើមអីទៅ អាកាំភ្លើងព្រៃយើងហ្នឹងណា មិនទាន់មានកាំភ្លើងស្វ័យប្រវត្តដូចយើងនៅ ឥឡូវនេះទេ ទាល់តែឆ្នាំ៧២-៧៣អីណោះបានមាន ដូចថានៅក្នុង៤-៥នាក់គឺមានពីរបី ដើមអីដែរ តែមិនទាន់មានអាការទេ គឺមានតែអាកាប៊ីនយើង ដល់យើងនៅឆ្នាំ៧៣មក គឺដល់បណ្តោយអាការ សុវ៉ាន់ធីធូរ អីដូចជាទ័ពយើងនៅខាង លន់ នល់ ដែរអាហ្នឹងគឺ នៅក្នុងឆ្នាំ៧៣ឡើងណា ។

វីណាៈ ហើយភូមិនេះពូថាមានខ្មែរក្រហមគេចូលមកតាំងពីឆ្នាំ៧០អញ្ចឹង?

ស៊ីនៈ ឆ្នាំ៧០ដែលវាបន្តឡើងនៅក្នុងឆ្នាំ៧០ ។

វីណាៈ អញ្ចឹងបានន័យថាភូមិនេះគឺឋិតនៅក្នុងការគ្រប់គ្រងរបស់ លន់ នល់ ទេមិនមែននៅក្នុង តំបន់រំដោះទេ?

ស៊ីនៈ ចាំ! នៅក្នុងការគ្រប់គ្រងរបស់ លន់ នល់ ប៉ុនយើងនៅក្នុងចន្លាត់ម៉ាត់ញកគឺគេចូលមក គ្រប់គ្រងដែរណា យើងចេញគឺគេចូល ដូចនៅក្នុងសម័យ លន់ នល់ ទ័ពគេនៅបាណន់ ណោះ ដល់អញ្ចឹងគេអ្នកដែលនៅខាងនេះគឺគេបន្តទ័ពមួយចំហៀងអញ្ចឹងគឺគេចូលមកដែរ បើថាមកជួបគ្នាទៅគឺបាញ់គ្នាទៅ បើថាមកមិនជួបទេក៏ធម្មតាទៅ ។

វីណាៈ ចុះគេចូលមកធ្វើអីដែរ?

ស៊ីនៈ ខ្លះទៅគឺគេចូលមកបំផុសបំផុលបំពាក់អារឿងនយោបាយរបស់គេនោះ គេនៅខាងនោះ គឺគេមានគោលនយោបាយរបស់គេនោះណា ហើយគេចូលមកបំពាក់យើងទៅណា គឺគេ អូសទាញយើងទៅជាមួយគេ ចូលទៅខាងគេហើយគេឲ្យយើងធ្វើទ័ពជាមួយគេ អាហ្នឹង នៅខាងគេហ្នឹងគឺគេធ្វើអញ្ចឹង ។

វីណាៈ ហើយពូថានៅពេលឆ្នាំ៧០ហ្នឹងគឺមានខ្មែរក្រហមមែនទែន?

ស៊ីនៈ ចាំ! អាហ្នឹងគឺខ្លាំងហើយ ។

វីណាៈ តើពូអាចនិយាយបន្តិចបានដែលទេ តើអាហ្នឹងវាយ៉ាងម៉េចទៅ?

ស៊ីនៈ កាលហ្នឹងនៅក្នុងឆ្នាំ៧០គឺគេកើតជាទ្រង់ទ្រាយធំណា ដល់អញ្ចឹងគេមានទ័ពគេរាប់រយ រាប់ពាន់មកច្បាំងជាមួយយើងណា ហើយគេមានសម្ភារះរបស់គេដូចជាយើងទ័ពនៅក្នុង សម័យ លន់ នល់ ដែរ ។

វីណាៈ គេមកពីខាងណាខ្លះ?

ស៊ីនៈ គេមកពីខាងលើអញ្ចឹងទៅគឺសុទ្ធតែជាប៉ែកខាងគេហើយ ចាប់ពីក្រោមទៅខាងណោះ អាហ្នឹងគឺនៅខាងយើង ។

វីណាៈ ខាងលើនៅខេត្តអីដែរ?

ស៊ីនៈ អានេះបើនិយាយទៅ វាស្រុកលើគឺព្រៃទេតែមិនដឹងជាគេដាក់នៅក្នុងខេត្តអីដែរ គឺយើង អត់មានដឹងទេណា គឺគ្រាន់តែគេហៅថាស្រុកលើ គឺសុទ្ធតែជាព្រៃហ្នឹង

គឺគ្មានភូមិគ្មានអី ទេ បើនិយាយទៅគឺ១០គីឡូពីនេះទៅគឺសុទ្ធតែជាព្រៃហ្នឹង អញ្ចឹងគេបានទ័ពគេទៅ ហើយដល់ពេលណាដែលគេនឹកឃើញទៅ គឺគេចូលមកវ៉ៃទ័ពយើងនៅខាងក្នុងនេះទៅ មួយប្រាវពីរប្រាវទៅ ហើយគេគៀរប្រជាជនទៅវិញទៅ ។

វីណា: គេគ្រាន់តែចូលមកវ៉ៃហើយទៅវិញអញ្ចឹង?

ស៊ីន: ចាំ! គឺគេគៀរប្រជាជានយកទៅ នៅក្នុងឆ្នាំ៧៣-៧៤គឺសុទ្ធតែគេគៀរយកទៅ ហើយ ដូចខ្ញុំនិយាយនៅខាងដើមមិញអញ្ចឹង យកទៅនៅជាមួយគេទៅ ហើយក្មេងៗចូលធ្វើទ័ព ជាមួយហ្នឹងគេទៅ ហើយស្រីៗនោះគេឲ្យនៅបំរើទ័ពគេក៏បាន ដឹកជញ្ជូនស្បៀងគេដែល នៅពេលដែលគេចុះមកវ៉ៃលើយើងនោះណា អាហ្នឹងគឺគេប្រមូលយកកំលាំង ។

វីណា: ចុងខាង លន់ នល់ អីនៅពេលដែលគេចុះមក គេអត់មានថាឲ្យទៅរស់នៅខាងតំបន់គេទេ តើគេចុះមកប្រាប់ថាម៉េចដែរ?

ស៊ីន: គេគ្រាន់តែថាឲ្យទ័ពចុះមកការពារយាមអីទៅ ហើយមួយថ្ងៃពីរថ្ងៃអីគឺគេចុះទៅវិញទៅ ហើយខាងគេនោះគេក្តាប់សភាពថាទាហានចុះ ហើយគេចូលមកអញ្ចឹងទៅ ហើយយើង ជាប្រជាជនគឺនៅកណ្តាលអញ្ចឹង ។

វីណា: ចុះគេអត់មានប្រាប់ថានេះជាតំបន់មុខគ្រាប់អី ហើយឲ្យជម្លៀសចេញអីអត់មានទេ?

ស៊ីន: អត់ទេ! អាហ្នឹងគឺស្រេចតែយើងទេ បើយើងខ្លាចគ្រាប់គឺយើងគេចចេញទៅ ទៅនៅ ក្រោមៗទៅគឺគេអត់មានថាអីទេ ។

វីណា: ចុះពេលនោះចំពោះពូផ្ទាល់ តើពូគិតថាចង់ទៅខាងណា ឬក៏គិតថាចង់ទៅនៅខាងលើ?

ស៊ីន: ខ្ញុំអត់មានចង់ទៅទេខាងលើ គឺខ្ញុំគិតថាចង់ទៅនៅខាងក្រោម ។

វីណា: ហើយចុះពូបានទៅដែលអត់?

ស៊ីនៈ ទៅ! យកប្រពន្ធកូនទៅដាក់នៅជិតបាត់ដំបងឯណោះ ទៅដាក់ដល់ហ្នឹងហើយខ្ញុំត្រឡប់មក នៅនេះវិញ ពីព្រោះយើងជាមនុស្សប្រុសណា មកមើលផ្ទះសំបែងខ្លះមើលគោក្របីខ្លះ ទៅ កូនចៅប្រពន្ធអីគ្នាតូចតាចយកទៅដាក់នៅហ្នឹងឯង អាហ្នឹងនៅក្នុងសម័យ លន់ នល់ ប៉ុនសម័យ លន់ នល់ គឺខ្ញុំមិនទាន់មានប្រពន្ធទេ តែដូចថាម្ដាយខ្ញុំអីអញ្ចឹងគឺបញ្ជូនគាត់ទៅ នៅខាងក្រោមទៅ ហើយខ្ញុំប្រឈមមុខជាមួយខ្មែរក្រហមនេះឯង ឆ្នាំ៧៣ឡើងទៅគឺ ថាខ្ញុំតាំងមុខនៅនេះឯង ខ្ញុំនេះទីតាំងខ្ញុំនៅវត្តនេះគឺសុទ្ធតែជាកាំភ្លើង សំរាប់តតាំងជាមួយហ្នឹងខ្មែរក្រហមនេះឯង ។

វីណាៈ ត្រឡប់ទៅប្អូនពូវិញ ថានៅពេលដែលខ្មែរក្រហមគេគៀរនៅពេលដែលមើលកុនអីហ្នឹង តើនៅពេលដែលគៀរទៅបាត់រហូតឬក៏យ៉ាងម៉េច?

ស៊ីនៈ បាត់រហូត តែនៅកាលហ្នឹងគឺខ្ញុំបានដឹងដំណឹងដែរកាលហ្នឹងណា ដឹងថាគេគៀរទៅខាងនោះហើយវានៅធ្វើទ័ពខាងគេនោះឯង ។

វីណាៈ ពូដឹងតាមណាដែរ?

ស៊ីនៈ កាលនោះបើនិយាយទៅ ដឹងតាមអាអ្នកដែលគេចូលមកវិញណា ដូចថាគេធុញទ្រាន់អារបបហ្នឹង ហើយគេរត់ចូលមកខាងយើញខ្លះណា ។

វីណាៈ នៅពេលណា?

ស៊ីនៈ គឺមាន មានអ្នកដែលគេរត់ចូលមកយើងខ្លះដែរ មិនមែនទៅបាត់រហូតទេ ជួនកាលនៅខាងណោះគេធុញទ្រាន់គេទៅ គឺគេរត់មកចូលនៅខាងយើងនេះវិញទៅ ហើយគេយកអាវុធអីមកសារភាពឲ្យយើងផង ហើយយើងឲ្យនៅទៅ អញ្ចឹងគឺយើងដឹងតាមរយៈហ្នឹង ឯង ។

វីណាៈ អំឡុងពេលហ្នឹងពូ មិនមែននៅក្រោយមកទេ?

ស៊ីនៈ	នៅក្រោយមក ។

វីណាៈ	ឆ្នាំណាដែរ?

ស៊ីនៈ	កាលណោះនៅពេលដែលវាចេញនៅឆ្នាំ៧២ ហើយដល់ឆ្នាំ៧៣អីណោះបានយើងដឹងដឹងដំណឹងថានៅពេលដែលវាទៅដល់ណោះ គឺគេឲ្យវាធ្វើទ័ពធ្វើអី ។

វីណាៈ	ចុះមានអ្នករត់ទៅដោយស្ម័គ្រចិត្តដែលទេពូ?

ស៊ីនៈ	មាន អ្នករត់ទៅដោយស្ម័គ្រចិត្តក៏មាន ទៅដោយគេបង្ខំក៏មាន ទៅដោយគេចាប់ទៅក៏មាន ។

វីណាៈ	ចុះអ្នកដែលទៅដោយស្ម័គ្រចិត្តហ្នឹង
តើគេយល់ឃើញថាម៉េចដែរបានជាគេរត់ចូលទៅ?

ស៊ីនៈ	អានេះដូចថាគេបំពាក់អាគោលនយោបាយយើងខ្លាំងពេក ហើយគេយល់ខុសហើយគេទៅតាមហ្នឹងទៅ ដូចថាមានខ្សែរយៈបងប្អូនគេទៅ ហើយគេចូលមកបំពាក់ទៅណា ថាចេះៗអីទៅ ម៉្លោះហើយអាម្នាក់ហ្នឹងជឿទៅ ហើយទៅតាមគេទៅ ។

វីណាៈ	ចុះពូថាដឹងដំណឹងពីប្អូនហ្នឹង ដឹងថាម៉េចទៅ ថាគាត់នៅធ្វើអីទៅ?

ស៊ីនៈ	លឺដំណឹងគេមកប្រាប់ថាប្អូនបងឯងទៅនៅធ្វើជាខ្មែរក្រហមទៅហើយ គេធ្វើទ័ពហើយកុំឲ្យភ័យព្រួយវាមិនអីទេ ពីព្រោះវាធ្វើទ័ពជាមួយគេហើយ ចុះគេគៀរយកទៅនោះ ។

វីណាៈ	ធ្វើទ័ពនៅណានៅណីអី គេអត់មានប្រាប់ទេ?

ស៊ីនៈ	នៅលើនោះ នៅលើដែលគេទៅក៏ទ័ពគេនៅក្នុងព្រៃនោះ ។

វីណាៈ	ចុះនៅពេលណាដែលគាត់ផ្លាស់ចេញពីហ្នឹង?

ស៊ីនៈ	អត់មានផ្លាស់ចេញផ្លាស់ចូលទេ ។

វីណាៈ

ចុះនៅពេលដែលពូថានៅពេលដែលខ្មែរក្រហមគេចូលមកវៃនៅក្នុងភូមិម្ដងៗអីនោះ?

ស៊ីនៈ	គេចូលមកវៃនៅពេលយប់អីអញ្ចឹងទៅ ហើយវាទៅវិញទៅ ។

វីណា៖ ចុះចាប់ពី៧៣ទៅនោះ?

ស៊ីន៖ អាហ្នឹងគឺគេវៃខ្លាំងហើយនៅក្នុងភូមិ ពីព្រោះខ្មែរក្រហមគេមានសម្ភារៈគេពេញណា ដូចថាគេមានសម្ភារៈគេដូចជា លន់ នល់ នោះជួនកាលគេមកវៃថ្ងៃអញ្ចឹងដែរ មកដួបទាហានយើងទៅ ១-២ថ្ងៃអញ្ចឹងទៅ បានជាវាត្រឡប់ទៅវិញទៅ ដូចថាទ័ពយើងវៃខ្លាំងបានវារត់ទៅ ដល់តែពេលយូរទៅយើងភ្លេចត្រចៀកទៅ វាចូលមកវៃយើងទៀតទៅ ។

វីណា៖ ចុះនៅពេលណាដែលវៃខ្លាំងអីអញ្ចឹង ដូចថាវៃផ្តាច់អីអញ្ចឹង?

ស៊ីន៖ ជួនកាលវាចូលមកវៃយប់ ហើយវៃទើសភ្លឺ វៃបន្ទាយទាហានណា ដូចថាបន្ទាយទាហានយើងនៅកន្លែងណាគឺវាមកព័ទ្ធវៃមួយយប់ទើសភ្លឺ ។

វីណា៖ ឆ្នាំណាដែរ?

ស៊ីន៖ ឆ្នាំ៧៤ ជិតចូល៧៥ហ្នុងអាហ្នឹងគឺខ្លាំងតែហ្នុង ។

វីណា៖ អញ្ចឹងដាច់នៅពេលណាដែរ?

ស៊ីន៖ ឆ្នាំ៧៥ហ្នឹងគឺគេផ្តាច់ហ្នឹងហ្នុង តែវាមិនវៃនៅមុខព្រួញនេះទេ គឺមុខព្រួញគេនៅខាងណោះណា ប៉ែកនៅខាងត្រើយម្ខាងនោះទេ ដល់អញ្ចឹងទៅវាចាប់បានអាប៉ុសវិទ្យុបាត់ដំបងទៅ វាផ្សាយបណ្តោយ ។

វីណា៖ ប្រកាសថាគេឈ្នះអីអញ្ចឹង?

ស៊ីន៖ ចា៎! វាថាឥឡូវបងប្អូនខ្មែរ ខ្មែរកុំឲ្យបាញ់ខ្មែរដាក់អាវុធរួបរួមគ្នាកសាងប្រទេស ឲ្យចងបាច់អាវុធទាំងអស់ ដល់យើងនេះលឺថាអញ្ចឹងម្នាក់ៗអរ! ព្រោះធ្វើជាទាហាន៤-៥ឆ្នាំដែរអញ្ចឹងវាមានការធុញទ្រាន់ ដល់តែលឺគេប្រកាសមកអញ្ចឹងវាអរ! ចុះគេប្រកាសថាឲ្យយើងឈប់បាញ់គ្នាទៅ កសាងប្រទេសម្តង ចងបាច់អាវុធរួបរួមគ្នាខ្មែរហ្នឹងខ្មែរទាហាន លន់ នល់ កម្ម៉ង់ជូរបាច់អាវុធដាក់បន្ទាយអស់ ដល់ខាងគេដឹងថាបាច់អាវុធអស់ហើយ មេបញ្ជាការគេខាងខ្មែរក្រហមនោះ បញ្ជារឡានមកយកអាវុធទៅដាក់នៅតាមឃ្លាំងអស់ ។

វីណា៖ រួចចុះមេៗទាហានយើងនោះ?

ស៊ីនៈ មេៗនៅតាមបន្ទាយហ្នឹង ប្រមូលគាំភ្លើងរួចហើយ គឺគេចាប់ផ្ដើមដឹកទ័ពគេចូលមក បណ្ដោយ ។

វីណាៈ ហើយចុះមេៗហ្នឹងក្រែងគេមានទំនាក់ទំនងទៅខាងភ្នំពេញអីដែរ?

ស៊ីនៈ មាន តែមិនដឹងជាយ៉ាងម៉េច ឲ្យតែមេដែលមានសក្តិបួនសក្តិប្រាំអីឡើងទៅគឺងាប់ទាំងអស់ បើតាមដែលខ្ញុំធ្លាប់បានគឺងាប់ទាំងអស់ ។

វីណាៈ ងាប់នៅឯណាដែរ?

ស៊ីនៈ ងាប់នៅតាមបន្ទាយនៅហ្នឹង គឺនៅពេលដែលដាក់អាវុធរួចទៅ មេៗគេនៅតាមកន្លែងចឹង ទៅណា ដល់ពេលវាប្រមូលអាវុធវាទៅដាក់នៅឃ្លាំងអស់ បានវាប្រើនយោបាយមួយ ថាឲ្យបងប្អូនណាទាំងអស់ដែលជាទាហាន ដែលមានបណ្ដាសក្តិពីសក្តិមួយឡើងទៅឲ្យទៅទទួលសម្តេច គេឲ្យទៅជួបជុំគ្នានៅសាលា អ៊ាខ យុគនេគយ៉ង់ យើងនៅបាត់ដំបងនេះណា ។

វីណាៈ សាលាអីគេពូ?

ស៊ីនៈ សាលាអ៊ាំយុគយើងនៅបាត់ដំបងនេះ ។

វីណាៈ សាលាហ្នឹងជាសាលាអីគេ?

ស៊ីនៈ សាលារៀន អនុវិទ្យាល័យយើងនេគយ៉ង់យើងនៅបាត់ដំបងហ្នឹង នៅជិតតាដំបងក្រញូង ឲ្យតែអ្នកមានបណ្ដាសក្តិមួយអីគឺទៅទទួលសម្តេចទាំងអស់ ពីព្រោះយើងអត់ដឹងនយោបាយរបស់គេគោលការណ៍របស់គេ ចុះយើងដាក់អាវុធទៅ គេថាយើងឈប់បាញ់គ្នាខ្មែរ ហ្នឹងខ្មែរអញ្ចឹង ដល់អញ្ចឹងយើងដាក់អាវុធឲ្យគេអស់ហើយ ដល់ពេលដែលវាប្រកាសថា អ្នកណាដែលមានបណ្ដាសក្តិឲ្យទៅទទួលសម្តេច ។

សិដ្ឋៈ ចុះឪពុកហើយហ្នឹងពូដែលធ្លាប់ធ្វើជាកម្ម៉ង់ដូរម៉េចបានជាអត់ទៅហ្នឹងគេកាលហ្នឹង?

ស៊ីនៈ ខ្ញុំអត់ទៅ ហើយឪពុកខ្ញុំគាត់ក៏អត់ទៅដែរ ។

វីណា: ចុះឪពុកពូគាត់ធ្វើជាអីដែរនៅកាលហ្នឹង?

ស៊ីន: គាត់ធ្វើជាកម្ម៉ង់ដូរនៅហ្នឹង ។

វីណា: កម្ម៉ង់ដូរហ្នឹងម៉េចទៅ?

ស៊ីន: ដូចជាទាហានអញ្ចឹងដែរ ។

វីណា: ចុះម៉េចបានជាគេមិនហៅជាទាហានទៅ?

ស៊ីន: គេហៅថាកម្ម៉ង់ដូរ អាមួយទាហាន ទាហានគេមានប្រាក់ខែ ហើយកម្ម៉ង់ដូរអត់មានប្រាក់ខែទេ តែធ្វើការសហការណ៍ជាមួយទាហាន អាហ្នឹងគឺវាចង់នៅលើទាហានទៀតពីព្រោះនៅជួរមុខទាហាន ។

វីណា: អត់មានប្រាក់ខែទេ?

ស៊ីន: អត់មានទេ ។

វីណា: អញ្ចឹងបានន័យថាយើងស្ម័គ្រចិត្តចូល?

ស៊ីន: បាទ! ពីព្រោះនៅកាលហ្នឹងគេឲ្យយើងជួយសហការណ៍ ។

វីណា: ចុះកាលពីមុនហ្នឹងពូធ្វើអីអញ្ចឹង?

ស៊ីន: ពីមុនខ្ញុំអត់មានធ្វើអីទេ ខ្ញុំជាប្រជាជនទេ តែឪពុកខ្ញុំគាត់ធ្វើជាជិទប់កាលពីមុនដែលយើងកើតសង្គ្រាមណា មុនឆ្នាំ១៩៧០ឪពុកខ្ញុំគាត់ធ្វើជាជិទប់ ។

វីណា: ចុះដល់ពេលក្រោយមក តើឪពុកពូគាត់ធ្វើអីដែរ?

ស៊ីន: សម័យដែលយើងធ្វើសង្គ្រាមមកឪពុកខ្ញុំគាត់ចូលធ្វើជាកម្ម៉ង់ដូរ ជាមួយហ្នឹងខ្ញុំហ្នឹងណា តាំងពីឆ្នាំ៧៣ឡើងមកគាត់ធ្វើជាប្រធានកម្ម៉ង់ដូរ ។

វីណា: អញ្ចឹងកម្ម៉ង់ដូរហ្នឹងទើបតែចាប់ផ្តើមធ្វើទេ?

ស៊ីន: ទើបតែចាប់ផ្តើមនៅឆ្នាំ៧៣ទេ ពីព្រោះនៅកាលណោះខ្មែរក្រហមគេចាប់ផ្តើមវៃខ្លាំងនោះ ហើយខាង លន់ នល់ គេឲ្យយើងរៀបចំកម្ម៉ង់ដូរសហការណ៍ជាមួយទាហានណា ហើយធ្វើជាកម្ម៉ង់ដូរគឺទិញកាំភ្លើងទៀតណាក្មួយ ។

វីណា: ទិញកាំភ្លើងពីខាងណា?

ស៊ីនៈ ទិញកាំភ្លើងពីខាងក្នុង

ខាងលើគេថាបើបងប្អូនណាចង់ការពារភូមិស្រុកខ្លួនឯងគឺមានលុយ ទៅទិញអាវុធទុកការពារ ដល់អញ្ចឹងពេលនោះអ្នកដែលដូចជាឪពុកខ្ញុំអញ្ចឹងដែលមាន លុយទៅទិញកាំភ្លើង មកម្នាក់មួយដើមៗទៅណា បាន៨-១០ដើមអញ្ចឹងទៅជួយយាម កាមនៅក្នុងភូមិអញ្ចឹងទៅ ក្រោយមកទៀតបានប្រហែលជា៣-៤ខែហ្នឹង បានគេអ្នក ដែលនៅខាងលើហ្នឹងគេបើកអាវុធមកឲ្យយើង អាហ្នឹងគឺយើងអត់មានទិញទេ បើកហ្នឹង គឺមិនមែនជាកាំភ្លើងអីទេ គឺមានតែអាកាប៊ីនយើងទេ ។

សិដ្ឋៈ អាហ្នឹងបាញ់មួយគ្រាប់ចេញមួយគ្រាប់?

ស៊ីនៈ អត់ទេ ចេញច្រើនគ្រាប់ដែរ តែភាគច្រើនវាខូច បើថាអាណានៅល្អវាអាចបាញ់បាន ខ្លះ ។

សិដ្ឋៈ ចុះពួថាអ្នកណាដែលមានបណ្ដាសក្តិ ហើយត្រូវបានគេប្រមូលផ្ដុំ ទៅឲ្យជួបគ្នានៅវិទ្យាល័យ នេតយ៉ង់ហ្នឹងណា ហើយក្រោយមកត្រូវគេចាប់ខ្លួន?

ស៊ីនៈ បាទ! គេចាប់ខ្លួន ។

សិដ្ឋៈ ចុះពួកកូនទាហាន តើគេយកទៅណាដែរ?

ស៊ីនៈ ទាហានគឺនៅតាមកន្លែងដល់តែយូរទៅ គេរំសាយទៅតាមផ្ទះទៅតាមអីទៅ ។

សិដ្ឋៈ តែពួកហ្នឹងនៅពេលក្រោយមកគេចាប់ខ្លួនដែលអត់ ឬក៏ក្លាយខ្លួនទៅជាប្រជាជនធម្មតា?

ស៊ីនៈ អាហ្នឹងគឺគេមកស្រាវជ្រាវតាមចាប់នៅតាមក្រោយទៀត តែសំខាន់អាមេៗមុន ។

វីណាៈ ហើយចុះមេៗហ្នឹង តើគេបញ្ជូនទៅណាដែរ?

ស៊ីនៈ ដូចខ្ញុំនិយាយថាគេឲ្យទៅជួបគ្នានៅសាលានេតយ៉ង់មិញហ្នឹង ហើយដល់ពេលដែលជួបជុំ គ្នារួច គេដាក់វិធានការយកឡានមកដាក់ទៅទទួលសម្ដេច តែត្រង់ថាទៅកន្លែងណាគឺខ្ញុំអត់ មានដឹងទេ តែគ្រាន់តែថាគេយកទៅទទួលសម្ដេច ។

សិដ្ឋៈ	តែក្រោយមកដូចថាមានដែលឃើញពួកគាត់ត្រឡប់មកភូមិវិញដែលអត់?

ស៊ីនៈ	មួយឡានទៅស្ងាត់ៗទៅ ។

វីណាៈ	ទៅច្រើនឡានដែលទេពូ?

ស៊ីនៈ	ទេបើគិតទៅគឺវាច្រើនឡាន
តែបើកាលហ្នឹងខ្ញុំក្តាប់បានដែរគឺវាដោយទាំងប្រជាពលរដ្ឋអ្នក ធាក់ល្មក អ្នកកាប់ជ្រូកអីណា ។

វីណាៈ	គេចាប់ដោយ?

ស៊ីនៈ	បាទ៎! ដល់តែលឺគេថាឲ្យទៅទទួលសម្តេចនាំគ្នាទៅទិញអាសក្តិគេមកពាក់ទៅតាមគេផាប់ ដែរ គឺគេយកទៅសម្លាប់ចោលទាំងអស់ ។

វីណាៈ	ចុះពូមានដឹងថាអ្នកដែលធ្វើជាមេទាហានពិតប្រាកដហ្នឹងទាំងអស់ប៉ុន្មាននាក់ដែរ តើពូមាន ដឹងទេ?

ស៊ីនៈ	ក្តាប់មិនបានទេ ។

វីណាៈ	ចុះពូមានស្គាល់អ្នកណាម្នាក់នៅក្នុងចំណោមហ្នឹងដែលទេ?

ស៊ីនៈ	នៅកន្លែងខ្ញុំនេះគឺខ្ញុំមានស្គាល់ខ្វះណា សក្តិបីគឺញឹក សក្តិពីរសាមឿន អាហ្នឹងមេធំនៅកន្លែងហ្នឹងហើយណា ។

សិដ្ឋៈ	អ្នកហ្នឹងសុទ្ធតែជាអ្នកដែលមានបណ្តាសក្តិពិត?

ស៊ីនៈ	ពីព្រោះសក្តិបីញឹកហ្នឹង គាត់ធ្វើជាគ្រូបង្រៀនផងណា ទីពីរបាន់ សាមឿនអីអាហ្នឹងគឺជាមេដែលនៅកន្លែងខ្ញុំហើយណា ។

វីណាៈ	កន្លែងពូនៅហ្នឹង តើគេហៅថាកន្លែងអីដែរ?

ស៊ីនៈ	អានេះគេហៅថាភូមិប៉ុសកន្ទឺ នេះកន្លែងដើមដូងនេះបន្ទាយគេហើយ ហើយមេៗខ្ញុំនៅកន្លែងនេះផាប់ទាំងអស់ ហើយស្តាប់ទៅមេៗដែលនៅខាងក្រោមណោះ ក៏គេយកមកសម្លាប់នៅនេះច្រើនដែរ នេះនៅផ្លូវយើងនេះនៅឯកភ្នំ ។

សិដ្ឋៈ	គេកន្លែងគេសម្លាប់នៅហ្នឹង?

ស៊ីនៈ អត់ទេ! គឺសម្លាប់នៅហ្នឹងថ្នល់ ទៅដល់វាសម្លាប់ហ្នឹងដាក់នៅជញ្ជើមថ្នល់ ទោះជាយើង ទៅកប់ក៏ដោយ មិនកប់ក៏ដោយ ហើយប្រជាជនយើងដែលដើរទៅតាមផ្លូវចេះតែឃើញ ទៅ គឺចេះតែអូសដាក់តាមជញ្ជើមផ្លូវទៅ ។

វីណាៈ ចុះកូនទាហានវិញ?

ស៊ីនៈ កូនទាហាននៅក្រោយពីពេលដែលវាហៅមេៗរួចទៅ វាស្រាវជ្រាវ ។

វីណាៈ ស្រាវជ្រាវរបៀបម៉េច?

ស៊ីនៈ ស្រាវជ្រាវតាមរយៈគ្នាគេនោះ ដូនកាលគេទៅនោះហើយគេមានបងប្អូនគេនៅក្នុងនេះ ដល់អញ្ចឹងនៅពេលដែលគេមកសួរបងប្អូនគេនៅនេះ ហើយថាអានេះធ្វើទាហាន ហើយ អានោះធ្វើកម្ម៉ង់ដូរទៅ ដល់ពេលនោះគេចាប់យកទៅសម្លាប់នៅតាមក្រោយ ។

វីណាៈ គេចាប់យកទៅសម្លាប់នៅឯណាខ្លះពូ?

ស៊ីនៈ ភាគច្រើនវាយកទៅដាក់គុកខ្លះ ។

វីណាៈ គុកនៅឯណាវិញ?

ស៊ីនៈ គុកនោបុរាណន់យើង អាគូរបុរាណន់យើង ។

រឿនៈ ដែលគេយកធ្វើជាអាងទឹកហ្នឹង?

ស៊ីនៈ ប៉ា!ៗ អានៅពីកើតហ្នឹង ភាគច្រើនគឺវាយកទៅដាក់គុកនៅហ្នឹង អាហ្នឹងគឺគេស្រាវជ្រាវ រកកូនទាហានដែលនៅក្រោយៗណា ដូចថាអ្នកណាដែលមានទំនាស់ជាមួយបងប្អូនវា ដែលនៅខាងក្នុងអញ្ចឹងទៅ គឺវាយកទៅបាញ់ចោលភ្លាម ។

វីណាៈ បាញ់ចោលនៅឯណាវិញ?

ស៊ីនៈ បាញ់ដាក់ចោលនៅតាមភូមិហ្នឹង ដូនកាលបាញ់ដាក់នៅមុខផ្ទះអញ្ចឹងទៅ អាអ្នកណាដូច ថាជាកូនទាហានល្មមៗ

គ្រាន់តែជាទាហានធម្មតាល្មមយកទៅដាក់គុកនៅកន្លែងគួរទៅ ហើយវាធ្វើទារុណកម្មទៅ ឲ្យស៊ីបាយដាក់... អានេះគឺវាដាក់ស្តែងហើយ ដូចជាអាអ្នកដែលរួចពីគុកមកណា ហើយខ្ញុំសួរ គឺគេបុកដីធ្វើជាកន្ទុកប៉ុណ្ណេះនៅក្នុងគុកណា ហើយវាដាក់បបរឲ្យយើងលិតដូចជាឆ្កែរអញ្ចឹង ។

វីណា: នៅគួរហ្នឹង?

ស៊ីន: បាទ! នៅកន្លែងគួរហ្នឹង ។

វីណា: ចុះពូម៉េចដឹងទៅ មានអ្នកគេរួចខ្លួនមក?

ស៊ីន: រួចមក ប៉ុនអ្នកដែលរួចមកស្លាប់ហើយ ។

វីណា: គាត់ឈ្មោះអីដែរ?

ស៊ីន: ឈ្មោះឡូន ។

វីណា: កាលមុនគាត់ធ្វើជាទាហាន?

ស៊ីន: អត់មានធ្វើជាទាហានទេ
អាហ្នឹងមិនដឹងជាយ៉ាងម៉េចទេគេចាប់ទៅប្រឡូ....វាចាប់យកទៅ ធ្វើជាទារុណកម្មណា តែដល់ក្រោយមកគឺវាលែងមកវិញណា វាលែងមកវិញប៉ុនហ្នឹងលែងគឺវាចង់ស្លាប់ហើយ អាហ្នឹងគឺឃើញមានតែមួយទេដែលរួចមកណា ។

វីណា: លែងមកវិញហ្នឹងលែងនៅឆ្នាំណា ហើយចាប់វិញចាប់នៅឆ្នាំណា?

ស៊ីន: ចាប់ហ្នឹងក្នុងឆ្នាំ៧៦ចូល៧៧ហើយ ចាក់ដាក់គុក វាបុកដីកន្ទុកប៉ុណ្ណេះឯងហើយវាដាក់បបរឲ្យយើងលិតទៅ ។

វីណា: ហើយគាត់រួចមកវិញហ្នឹង គឺគេលែងគាត់មិនមែនគាត់លួចរត់ទេ?

ស៊ីន: អត់ទេ! មិនដឹងជាគេស្រាវជ្រាវយ៉ាងម៉េចទេស្រាប់តែគេលែងមកវិញ ។

វីណា: ឆ្នាំណា?

ស៊ីន: ដើមឆ្នាំ៧៧ហ្នឹងឯង ចុងឆ្នាំ៧៦ចូល៧៧ហ្នឹងឯង គឺឃើញមានរស់មួយហ្នឹងឯង ។

វីណា: ចុះពេលដែលគេលែងមក តើគាត់មកនៅឯណាវិញ?

ស៊ីនៈ	លែងមកនៅភូមិខ្ញុំនេះវិញ ។

វីណាៈ	គាត់បាននិយាយប្រាប់អីខ្លះដែរ?

ស៊ីនៈ	គាត់និយាយប្រាប់ពីរឿងសភាពដែលវាយកទៅធ្វើបាប ធ្វើទារុណកម្មនៅក្នុងហ្នឹង ដូចថា ទៅដល់នៅក្នុងអញ្ចឹងគឺវាដាក់ខ្នោះជើងទាំងអស់ ។

វីណាៈ	សុទ្ធតែជាប្រុស?

ស៊ីនៈ	សុទ្ធតែជាប្រុសអត់មានស្រីៗទេ ដល់នេះទៅវាឲ្យយើងទៅធ្វើការហើយវាមានទាហានរបស់វានៅយាម ហើយដល់មកវិញវាដាក់ខ្នោះជើងយើងទៅ ហើយឲ្យបបរឲ្យយើងស៊ី តិចៗទៅ ហើយជួនកាលអត់មានអីឲ្យស៊ីទៀត គឺស៊ីអាបន្លែយដែលនៅក្នុងហ្នឹងទៅ ដូចថា បន្លយវារត់កាត់ទៅចាប់បានទៅក៏ស៊ីទៅ ។

វីណាៈ	ចុះនៅកន្លែងគុកហ្នឹងឥឡូវមានសល់ស្លាកស្នាមអីដែលទេ?

ស៊ីនៈ	អត់មាននៅសល់ទេ បាត់អស់ហើយពីព្រោះគេធ្វើស្រែអីអស់ហើយ ។

វីណាៈ	គេអត់មានសម្លាប់នៅកន្លែងហ្នឹងទេ គឺគេគ្រាន់តែយកទៅដាក់គុកតើ?

ស៊ីនៈ	ទេ! សម្លាប់នៅកន្លែងហ្នឹង ឆ្នាំ៧៦ដែលដាក់អាវុធណា គឺគំនរខ្មោចដូចជាស្អីអញ្ចឹង ។

វីណាៈ	ហើយឆ្អឹងគេយកទៅណាវិញ?

ស៊ីនៈ	ប៉ុនឥឡូវវាអាពាត់អារ៉ាយអស់ហើយ ពីព្រោះគេធ្វើស្រែនោះ គេភ្ជួរគេអី ។

វីណាៈ	គេអត់មានប្រមូលឆ្អឹងអីមកទុកទេ?

ស៊ីនៈ	អត់មានពីណាគេប្រមូលទេក្មួយអើយ គំនរឆ្អឹងដូចជាឡានអញ្ចឹង មួយដុបៗខ្មៅអូញ អញ្ចឹង ដូចថាមុនអាយើងដែលរំដោះបានហ្នឹង គឺវាសម្លាប់អាអ្នកទោសដែលនៅក្នុងគុកហ្នឹងណា ចេញមកសម្លាប់ដាក់មួយដុបៗនៅកន្លែងគូរខាងកើតស្ពានហ្នឹងណា នៅកន្លែងអាងគេហ្នឹងកន្លែងទំនាបកន្ទុកគេហ្នឹង ។

រឿនៈ	ពីណាគេប្រធានគុកនៅហ្នឹងពូ?

ស៊ីនៈ	អត់ស្គាល់ទេ អត់ស្គាល់ច្បាស់ទេអាប្រធានគុកគេហ្នឹង ។

រឿនៈ ប្រធានសន្តិសុខអីមាននៅរស់ដែលទេ?

ស៊ីនៈ អត់ក្តាប់បានទេ ប៉ុនអាមេពិជយាដដែលដើរចាប់សម្លាប់នៅតាមភូមិ អាហ្នឹងគឺវាស្លាប់ហើយ ។

វីណាៈ ឈ្មោះអីគេដែលពូ?

ស៊ីនៈ ឈ្មោះផល អាហ្នឹងវាស្លាប់ដោយសារលេបថ្នាំខ្លួនវា ។

វីណាៈ ម៉េចអញ្ចឹង?

ស៊ីនៈ មិនដឹងដែរ អាហ្នឹងស្លាប់នៅក្នុងឆ្នាំ៧៧ហើយ ។

វីណាៈ លេបថ្នាំសម្លាប់ខ្លួន?

ស៊ីនៈ លេបថ្នាំសម្លាប់ខ្លួន ។

វីណាៈ ចុះផលហ្នឹងគាត់ធ្វើតាំងពីពេលណាមក?

ស៊ីនៈ មិនដឹងជាពីឆ្នាំណា ។

វីណាៈ ចុះពូឃើញមុខគាត់នៅឆ្នាំណា?

ស៊ីនៈ នៅក្នុងឆ្នាំ៧៥ ។

វីណាៈ ចុះមុន៧៥គាត់នៅឯណា?

ស៊ីនៈ បើទៅមុនហ្នឹង មិនដឹងជាគេចេញទៅ នៅឆ្នាំណាគឺយើងអត់មានបានក្តាប់បានទេណាតែ នៅក្នុងឆ្នាំ៧៥គឺឃើញមុខគេមកបណ្តោយ ។

វីណាៈ មានតែម្នាក់ហ្នឹងទេ?

ស៊ីនៈ មានច្រើនណាស់ តែយើងអត់មានស្គាល់មុខគេទេ គឺយើងស្គាល់តែម្នាក់ហ្នឹងទេដែលច្បាស់ នៅភូមិខាងលើនេះ បន្ទាប់ពីភូមិខ្ញុំទៅគឺគេហៅថាភូមិត្រសរពួក ។

វីណាៈ ឃុំកន្ទឺហ្នឹង?

ស៊ីនៈ ឃុំកន្ទឺ១ហ្នឹងដែរ គេនៅហ្នឹងដែរពីដើមណា គឺវាមានអាក្នុងអញ្ចឹងដែរ ហើយយើងចង់លាក់វាក៏អត់ជិតដែរ ។

វីណាៈ ចុះមានអ្នកផ្សេងទៀតដែលទេ ដែលពូបានស្គាល់?

ស៊ីនៈ ស្គាល់ច្រើន ប៉ុនពួកអាហ្នឹងវាបាត់អស់ហើយ ស្លាប់អស់ហើយ ។

វីណាៈ មានឈ្មោះអីខ្លះ?

ស៊ីនៈ គេហៅថាអាឆៃយាន អាផល អាឌុង អាហ្នឹងគឺជាមេខ្លាំងៗគេហើយ ។

វីណាៈ ពួកហ្នឹងមានឋានៈអីដែរ?

ស៊ីនៈ អាហ្នឹងមិនដឹងជាឋានៈអីទេ ប៉ុនអាហ្នឹងដែលគេចាប់អីគឺមានមុខគេហើយ ដូចថាខ្ញុំអីអញ្ចឹង មានទោសអញ្ចឹងគឺគេមកហើយ អ្នកទាំងប៉ុន្មាននាក់ហ្នឹងណាដែលមកចាប់ គឺគេជិះសេះគេ មកហើយ សេះគេពីរបីហ្នឹង... ។

វីណាៈ ចុះគណៈឃុំនៅជំនាន់ហ្នឹងឈ្មោះអីគេដែរ?

ស៊ីនៈ ឈ្មោះ ហាន់ ធីៗ ឈ្មោះក្រៅមិនដឹងជាហៅស្អីទេ .....តាម៉ង់ គឺភាគច្រើនគេហៅថា តាម៉ង់ ។

វីណាៈ គាត់កាចឬស្លូត?

ស៊ីនៈ ទេនៅជំនាន់ហ្នឹងមិនដឹងដែរ តែមើលទៅដូចជាមិនស្លូតប៉ុន្មានទេ ពីព្រោះគេជាមេហើយ ។

វីណាៈ គាត់នៅឯណាដែរ?

ស៊ីនៈ គាត់មកពីស្រុកបាណន់ គាត់នៅកន្ទឺ២ ។

វីណាៈ ហើយពូមានដែលជួបអ្នកណាដែលរត់ទៅ នៅមុនជំនាន់៧៩អីចឹងណា អ្នករត់ពីភូមិនេះទៅ ហើយទៅចូលខាងខ្មែរក្រហមអីអញ្ចឹងណា ហើយគេត្រឡប់មកភូមិវិញហើយគេមកកាន់ កាប់យើងវិញអីមានដែលទេ?

ស៊ីនៈ មុនឆ្នាំ៧៥! ។

វីណាៈ ដល់ពេល៧៥ហើយគេមកធ្វើការនៅក្នុងភូមិនេះវិញមានដែលទេ?

ស៊ីនៈ អត់ទេ! គ្មានទេ ។

វីណាៈ ចុះឪពុកពូ?

ស៊ីនៈ ឪពុកខ្ញុំខ្មែរក្រហមសម្លាប់ដែរ?

វីណាៈ នៅឆ្នាំណាដែរ?

ស៊ីនៈ ខ្ញុំវាមិនបានគិតពីរឿងឆ្នាំ តែប្រហែលជានៅក្នុងចុងឆ្នាំ៧៦ហ្នឹងដែរ ។

វីណាៈ ដោយសារអីដែរ?

ស៊ីនៈ ដូចខ្ញុំបានជំរាបពីខាងដើមអញ្ចឹង គឺគាត់ធ្លាប់ធ្វើជាទាហានកម្ម៉ង់ដូរ ។

វីណាៈ ចុះពូហេតុអីបានជាគេអត់ចាបប់ពូ
ហើយគេអត់មានរកឃើញថាពូធ្វើជាកម្ម៉ង់ដូរអីចឹង?

ស៊ីនៈ ពេលហ្នឹងគឺវារកដែរ ប៉ុនកាលហ្នឹងនៅពេលដែលឆ្នាំ៧៥ដាក់អាវុធ គឺខ្ញុំដឹងថាវាមករកខ្ញុំ ហើយខ្ញុំរត់ទៅបួស ។

វីណាៈ ទៅបួស! ពូបួសបានដែរ?

ស៊ីនៈ បាទ! ទៅបួសបាន ។

រឿនៈ ឪពុកពូរត់ទៅបួសដែរ?

ស៊ីនៈ គាត់រត់ទៅបួសដល់វត្តស្លក្រោមណោះ ។

សិដ្ឋៈ ចុះពូទៅបួសនៅវត្តណា?

ស៊ីនៈ ខ្ញុំទៅបួសនៅវត្តបាណន់ ដំបូងអានេះគឺខ្ញុំនិយាយពីដំបូង ដំបូងកាលនៅឆ្នាំ៧៥ខ្ញុំដាក់អា វុធប្រើប គឺអត់ទាន់រត់ទៅបួសភ្លាមទេ ដល់ឃើញហេតុការណ៍ដែលវាដើរចាប់អាអ្នកដែល ទំនាស់ៗជាមួយវានៅតាមភូមិហ្នឹង ដូចថាខ្ញុំទំនាស់ជាមួយវាអញ្ចឹង ហើយវាចេញទៅ ណោះណា ដល់តែវាមកវិញវាចាប់ខ្ញុំទៅសម្លាប់ អត់មានពិបាកយកទៅណាទេគឺវាយក ទៅបាញ់ចោលនៅតាមផ្លូវអញ្ចឹង ដល់តែខ្ញុំដើរឃើញវាសម្លាប់ភាគច្រើនអញ្ចឹងទៅ គឺខ្ញុំអត់មានទុកចិត្តខ្លួនខ្ញុំទេណា ហើយនៅក្នុងភូមិខ្ញុំនេះសម្លាប់មួយហើយ សម្លាប់នៅ ត្រង់ណោះម្នាក់ អញ្ចឹងខ្ញុំមិនទុកចិត្តមិនស្រួលវាសម្លាប់ហើយ ដល់អញ្ចឹងខ្ញុំរត់ទៅបួស ដល់រត់ទៅបួយបានប្រហែលជាពីរខែឬបីខែទេ

ដល់តែទៅបួសហ្នឹងគឺវាទៅចាប់ទាំងលោក ទៀត ដល់អញ្ចឹងវានាំគ្នាទៅចាប់លោកនៅវត្តបាណន់ដែលទៅបួសហ្នឹងណា គឺវាទៅចាប់អាអ្នកដែលមានទោសដូចជាខ្ញុំទៅបួសដែរ ។

វីណា: អញ្ចឹងមានអ្នករត់ទៅបួសច្រើនដែរ?

ស៊ីនៈ រត់ទៅបួស៥-៦នាក់ណោះ ដល់អញ្ចឹងទៅវាស្រាវជ្រាវឃើញថារត់ទៅបួស គឺវាទៅ ចាប់ទាំងលោក ប៉ុននៅខាងខ្ញុំនេះគឺវាស្រាវជ្រាវអត់ដឹងខ្ញុំទេ ដល់វាទៅស្រាវជ្រាវនៅ ភូមិគេណោះដឹងថារត់ទៅបួសនៅហ្នឹងដែរ ដល់តែពេលយប់ហ្នឹងវាទៅចាប់ ហើយខ្ញុំនៅ ហ្នឹងដែរ កាលហ្នឹងប្រហែលជានៅម៉ោង៥-៦ល្ងាចណា ដល់ធ្វើអីរួចទៅក៏អង្គុយនៅមុខកុដ្ឋិហ្នឹងរៀនធម៌អីលោកនោះ ស្រាប់តែមានគ្នា៥-៦នាក់ខ្មែរក្រហមហ្នឹងណា ហើយគេសួរថាខ្ញុំគេជគុណៗមានស្គាល់ឈ្មោះតាមឿន តាឆនទេ គឺវាសួររកឈ្មោះតាមឿនហ្នឹងតាឆន គឺតាមឿនតាឆនហ្នឹងគាត់មានទោសហើយគាត់រត់ទៅបួស គឺគាត់ធ្វើជាកម្មុំងដូរជាមួយហ្នឹងខ្ញុំដែលនោះ ហើយគាត់រត់ទៅបួស ហើយមានចាប់អារម្មណ៍ថាគេសម្លាប់លោកឯណា គឺខ្ញុំគិតថារត់ទៅបួសហើយគឺគេឈប់សម្លាប់ហើយ ដល់អញ្ចឹងខ្ញុំក៏ប្រាប់ត្រង់ទៅណាក្មួយ ប្រាប់ថាលោកតាមឿនហ្នឹងតាឆនគាត់នៅកុដ្ឋិនោះ ដល់ខ្ញុំចង្អុលទៅចុះ ស្រាប់តែគេទៅតាមអាដៃហ្នឹងទៅ ដល់អញ្ចឹងខ្ញុំដើរទៅតាមក្រោយព្រោះឃើញដូចជា រៀងមិនទុកចិត្ត ព្រោះនៅម៉ោងប្រហែលជា៦យប់ណាព្រិលៗ ហើយគេមានគ្នា៥-៦ នាក់កាន់កាំភ្លើងនឹកស្មានថាបងប្អូនគេមកលេងណា គេស្គាល់គេអីណា ដល់វាទៅវាទៅនិមន្តលោកតាឆន ដល់វាទៅខ្ញុំដើរទៅតាមក្រោយមួយៗ ខ្ញុំអត់មានហ៊ានទៅជិតទេ គឺខ្ញុំ ដើរគ្រាន់តែតាមមើលណា ដល់ឃើញគេទៅដល់កុដ្ឋិលោកតាឆនហ្នឹងតាមឿនហ្នឹងគេ មិនហៅចំឈ្មោះទេ គឺគេហៅថាគេជគុណៗលោកទាបៗនៅហ្នឹងលីហើយស្រែកប្រាប់

ថាលោកតាមឿនហើយហ្នឹងតាឆនកំពុងតែរៀនធម៌នៅក្នុងបន្ទប់ ហើយស្រែកសួរថាមាន ស្គាល់លោកតាមឿនហ្នឹងតាឆនដែលទេ លោកដែលនៅកុដ្ឋិជិតនោះលឺ ហើយស្មានថាបង ប្អូនអីមកលេងដែលនោះ ក៏ប្រាប់ថាលោកសឹងកំពុងតែរៀនធម៌ ដល់អញ្ចឹងវាថាគេជ- គុណហៅកុរណាបន្តិច ពីព្រោះកុរណាចង់ជួបមានការ ដល់លោកហ្នឹងទៅហៅលោកតាឆន ហើយហ្នឹងតាមឿនមក ហើយវានៅឈរនៅហ្នឹងដីមុខកុដ្ឋិហ្នឹង កុដ្ឋិថ្មណាហើយជណ្ដើរក៏ ជណ្ដើរថ្មដែរ ដល់អញ្ចឹងវាឈរចាំអញ្ចឹង ដល់លោកតាមឿនលោកឆនចុះមក ហើយ លោកស្មានតែមានបងប្អូនគាត់មកលេង គឺស្មៀកតែស្បង់ទេអត់មានជីពរទេចុះមក គឺ លោកតាមឿនចុះមកមុនហើយលោកតាឆនចុះមកតាមក្រោយ ដល់ចុះមកប្រិបៗជិត ដល់អាកាំជណ្ដើរអស់ទៅ ហើយហ្នឹង គេចាប់លោកតាមឿនពីប គេក្រសោបចាប់លោក តាមឿនពីប ហើយលោកតាឆនចុះមកតាមក្រោយហ្នឹង ដល់ឃើញវាចាប់លោក តាមឿនពីមុខនោះ លោកតាឆនលោតធាក់អាពួកហ្នឹង ដល់តែលោតធាក់ទៅវាបែក ខ្ចាយអញ្ចឹងទៅ លោករត់រួចបណ្ដោយទៅគឺលោកតាឆនហ្នឹងណា ចំណែកលោកតាមឿន ដែលចុះមកមុនគឺវាចាប់ជាប់បាត់ហើយ ។

វីណា: គេចាប់ពីបហើយយកទៅធ្វើអីទៀត?

ស៊ីនៈ ចាប់ហើយគេយកទៅបាញ់ចោលនៅឈើទាល ដែលគេហៅថាតាក្របោរៗណា គឺគេ យកលោកតាមឿនមកបាញ់ចោលនៅហ្នឹងទៅ លោកតាឆនគាត់រត់រួច ដល់អញ្ចឹង និយាយពីរឿងខ្ញុំវិញ គឺលោកតាឆនរត់រួចហើយលោកតាមឿនគេចាប់បានចល្វាចហ្នឹង ដល់ខ្ញុំនឹកឃើញថាអញភ័យខ្លាចវាសម្លាប់ខំរត់ទៅបួស ដល់ឥឡូវវាទៅចាប់ទាំងបួស អញ្ចឹងក៏សុំលោកសឹកមកវិញណា ហ៊ឺ..ហ៊ឺៗ! សុខចិត្តបើថាឲ្យវាចាប់សម្លាប់គឺសម្លាប់ជា ប្រុសក់ទៅចុះ គឺសុខចិត្តសុំលោកគ្រូស្រែក្រោចហ្នឹងសឹកមកវិញ សឹកមកហ្នឹងខ្ញុំមិនទាន់ មកនៅផ្ទះវិញទេ គឺខ្ញុំទៅនៅគល់ណោះ ហើយប្រពន្ធខ្ញុំនេះមិនទាន់បានទេ ប្រពន្ធខ្ញុំនៅ

ក្នុងក្រុមនៅភ្នំគល់ណោះ ហើយខ្ញុំទៅនៅភ្នំគល់នោះឯង ទៅនៅអែបៗហ្នឹងឯង នៅយប់ ឡើងខ្ញុំទៅសុំបាយប្រពន្ធខ្ញុំហ្នឹងប្រជាជនដែលនៅក្នុងក្រុមហ្នឹងណា ហើយគេអាណិតខ្ញុំណា គេចេះតែឲ្យបាយទឹកអីហូបអញ្ចឹងទៅ ហើយនៅពេលថ្ងៃអីមិនដែលដើរចេញទេពីព្រោះ យើងខ្លាចវាឃើញមុខយើងណា យប់ឡើងគឺចេះតែចូលទៅ ហើយគេចេះតែអាណិតខ្ញុំ ចេះតែឲ្យបាយទឹកអីហូបអញ្ចឹងទៅ ខ្ញុំនៅហ្នឹងរហូតទាល់តែខ្ញុំមើលទៅ ទាល់តែអាមេពេជឃាដហ្នឹងវាស្លាប់ ដល់ពេលដែលវាស្លាប់គឺខ្ញុំចេញមក ហើយពួកអាមេផ្សេងៗវាផ្លាស់អស់ណា ហើយវាអស់អាអ្នកដែលស្គាល់នៅនេះហើយ ដល់អញ្ចឹងខ្ញុំចេញមកបានប្រពន្ធខ្ញុំនេះរៀបចំសែនទៅ ហើយកាលហ្នឹងវានៅមានលោកនៅឡើយ ហ្នឹងគឺនៅមាននិមន្តលោកអី មកសូត្រមន្តអីបានហ្នឹង ខ្ញុំឲ្យម្តាយខ្ញុំទៅនិយាយទៅក៏បាន រៀបចំមានសែនព្រេនអី តែគ្មានផ្ទេរការអីទេ តែបាននិមន្តលោកសូត្របាន ។

វីណាៈ នៅឆ្នាំណាដែរ?

ស៊ីនៈ នៅក្នុងឆ្នាំ៧៥ហ្នឹងដែរ តែមិនទាន់ចូល៧៦ទេ តែវានៅលោកមិនទាន់ផ្តាច់លោកទេ ដូចខ្ញុំនិយាយពីមុនអញ្ចឹង គឺពេលដែលវាចូលមកភ្លាមគឺមិនទាន់ផ្តាច់ភ្លាមទេ គឺវានៅប្រើលោកធ្វើពលកម្មនៅឡើយហ្នឹង វានៅប្រើលោកឲ្យទៅជីកទំនប់ទឹកជីកប្រឡាយអីនៅឡើយហ្នឹង ។

វីណាៈ ចុះដល់ពេលក្រោយមកម៉េចដែរ?

ស៊ីនៈ ក្រោយមក គឺលោកសឹកដោយខ្លួនឯងទេ ។

វីណាៈ ប៉ុន្មានខែបានលែងមានលោកមានអីទៀត?

ស៊ីនៈ ចូល៧៦ហើយ គឺចូលឆ្នាម៧៦ហ្នឹងគឺលោកដាច់អស់ហើយ ហើយលោកសឹកខ្លួនឯងខ្លះទៅ ។

វីណាៈ សឹកខ្លួនឯងផង គេផ្សឹកផង?

ស៊ីនៈ សីកខ្លួនឯងផង គេផ្សឹកផងអស់មួយវត្តទៅ វាទៅវត្តមួយទៀតដល់អញ្ចឹងទៅ វាទៅអស់ បណ្តោយគឺទៅឯងបណ្តោយ ។

វីណាៈ គេផ្សឹកម៉េចទៅ?

ស៊ីនៈ គឺវាលោកជាអ្នកដែលគេងប្រវ័ញ្ចពលកម្មគេ វាថាអញ្ចឹងវាថាលោកបួសអត់ធ្វើការគេង ប្រវ័ញ្ចពលកម្មគេ ស៊ីដោយសារតែគេគឺវានិយាយអញ្ចឹង ដល់អញ្ចឹងទៅ លោកសឹកអស់ គឺសឹកដោយខ្លួនឯងទៅ ។

វីណាៈ ចុះលោកតាឆនដែលរត់រួចហ្នឹងមានដែលត្រឡប់មកវិញដែលទេ?

ស៊ីនៈ ប្រវត្តលោកតាឆនហ្នឹងដែលគាត់រត់រួចទៅ គឺគាត់រត់ទៅ នៅតាមត្របូកស្រែគេណាក្លួយ ចុះកាលនោះគេរួមក្រុម សូម្បីតែអង្ករមួយកំប៉ុងក៏វាមិនទុលឲ្យយើងមាននៅហ្នឹងផ្ទះដែរ ចានមួយក៏វាមិនទុកឲ្យយើងដែរ ស្លាបព្រាមួយក៏វាមិនទុកឲ្យយើងនៅតាមផ្ទះដែរ គឺវាប្រមូលយកទៅដាក់រួមទាំងអស់ នៅពេលហ្នឹងតាហ្នឹងគាត់រត់រួចទៅណោះ និយាយពីរឿងតាហ្នឹងវិញ គាត់អត់មានអីហូបទេព្រោះគាត់នៅក្នុងដីបូកស្រែគេ បើចូលទៅនៅ ក្នុងក្រុមគេគឺឃើញគេសម្លាប់ ដល់អញ្ចឹងទៅ នៅរស់នៅក្នុងព្រៃនៅតាមដីបូកស្រែទៅ យូរៗទៅលួចចេញទៅសុំបាយអ្នកស្រុកប្រពន្ធគាត់នោះ ដល់លួចចេញទៅយូរៗគេតាម ដាន គេដាក់ខ្សែរបន្ទាត់នៅនេះណា គេតាមដានដឹងថាតាហ្នឹងសុំបាយប្រពន្ធអី គេក្តាប់ បានថាប្រពន្ធនៅក្រុមណា គឺគេមកដាក់ខ្សែបណ្តាញនៅក្នុងក្រុមហ្នឹង ពីមុនហ្នឹងគឺគេដាក់ ក្រុមរួមណាអូន គឺបបររួមបាយរួមណា ដល់អញ្ចឹងទៅគឺគេស្រាវជ្រាវតាហ្នឹង គឺដឹងថា ប្រពន្ធនៅឯណា ឧទាហរណ៍ថាប្រពន្ធនៅក្នុងភូមិខ្ញុំអញ្ចឹង គឺគេដាក់ខ្សែរត្រៀមនៅក្នុងភូមិ ខ្ញុំអញ្ចឹង ។

វីណាៈ អញ្ចឹងគេស្រាវជ្រាវតាមខ្សែររយះប្រពន្ធ?

ស៊ីនៈ បាទ! គេស្រាវជ្រាវតាមរយៈបងប្អូនហ្នឹងប្រពន្ធ ដល់អញ្ចឹងអ្នកហ្នឹងលួចមកសុំបាយទឹកអី យូរៗគឺគេឃើញ

ដល់គេឃើញអញ្ចឹងគេរាយការណ៍ទៅពទ្ធ័កន្លែងដឹបូងស្រែហ្នឹងងាប់ទៅ

ក្រោយមកសម្លាប់ដដែល ។

វីណាៈ អញ្ចឹងនៅពេលដែលគាត់ចេញពីវត្តហ្នឹងគឺគាត់សឹកដោយខ្លួនឯង?

ស៊ីនៈ សឹកខ្លួនឯង គឺគ្មានអ្នកណាមកសឹកទេ អញ្ចឹងបានតែថាវាសសាហាវព្រៃផ្សៃណាស់ ៣ឆ្នាំ៨ខែ២០ថ្ងៃហ្នឹងនោះ ។

វីណាៈ ចុះពូថាអ្នកដែលមកចាប់លោកហ្នឹងទាំងអស់ប៉ុន្មាននាក់?

ស៊ីនៈ ៥-៦នាក់ ។

វីណាៈ ចុះពូមានស្គាល់អ្នកណាដែលម្នាក់ដែលទេ?

ស៊ីនៈ អត់ស្គាល់ទាំងអស់ ពីព្រោះវាមកនៅពេលយប់ព្រលប់ៗណា ហើយតូចៗនៅក្មេងៗ ។

វីណាៈ ខ្លួនអាយុប៉ុន្មានដែរ?

ស៊ីនៈ ខ្លួនអាយុប្រហែលជានៅ១៥-១៦ឆ្នាំប៉ុណ្ណឹង កាំភ្លើងស្ពាយសឹងតែមិនផុតដីផង នៅក្នុង សម័យហ្នឹងប្រជាពលរដ្ឋអត់មានគំនិតគិតថាទៅណារួចទេ កាលដែលវាចាប់ដឹកមក សម្លាប់ទាំងឡានៗគឺអត់មានចងទេក្មួយ គឺវាអត់មានចងក្រព័ទ្ធសេកដាក់មកក្រោយអញ្ចឹង ទេគឺវាដាក់យើងនៅលើឡានធម្មតាអញ្ចឹង វាបើកមកដល់កន្លែងដែលវាសម្លាប់គឺវាឲ្យ អោយយើងចុះហើយវាសម្លាប់ប្រាវៗ ហើយរួចបានវាទៅវិញ ។

សិដ្ឋៈ ពូបានឃើញផ្ទាល់ភ្នែកដែរ?

ស៊ីនៈ បាទ! ហើយប្រជាជនពេលហ្នឹងមិនដឹងថាម៉េច មិនបានគិតអីឲ្យបានវែងឆ្ងាយសោះ គឺឲ្យ វាយកទៅសម្លាប់ស្រួលៗ គឺអត់មានរត់ទៅឯណាអីសោះ អាហ្នឹងគឺវាឃើញជាក់ស្តែង ណាក្មួយ គឺនៅពេលដែលខ្ញុំនៅបួសហ្នឹងគឺខ្ញុំទាន់អាវាយកមកសម្លាប់ពីរបីឡាន វាចាប់

យកមកពីក្រោមណោះកាលណោះខ្ញុំបួសនៅវត្តបាណន់ហ្នឹង ហើយប៉ុសវានៅជិតកន្លែង វត្តហ្នឹងក្លួយ ហើយពេលវាចាប់បានពីណាមកគឺមេធំវាហ្នឹងឲ្យចូលទៅកន្លែងវាសញ្ញេរសិន គឺសញ្ញេរសិនបានគេឲ្យយកម្នាក់ហ្នឹងទៅសម្លាប់បាន បើថាមេធំគេមិនឯកភាពទេគឺអ្នកឯង មិនអាចយកទៅសម្លាប់បានទេ ។

រឿនៈ ពូមានដែលស្គាល់មេធំគេហ្នឹងដែលទេ?

ស៊ីនៈ ខ្ញុំអត់ស្គាល់ទេវាដឹងអត់ច្បាស់ ហើយខ្ញុំវាភ័យពេកអត់មានគិតសួរនាំអាមេអី ៗ ទេពីព្រោះ យើងវាមានរឿងដែលណា ដល់អញ្ចឹងវាចូលទៅសញ្ញេរ ហើយវាដាក់ឡានយើងនីសាន់ យកទៅ ប្រហែលជាមានខ្ទង់ដប់អ្នកជាង ហើយយកទៅដល់វាចូលទៅកន្លែងវាពីប គឺវា ចូលទៅសញ្ញេរជាមួយហ្នឹងមេវាសិន ដល់សញ្ញេរអីរួចបានវាយកទៅសម្លាប់នៅអាកន្លែង ទួលអីមិញដែលខ្ញុំនិយាយហ្នឹងណា គឺគេឲ្យយកទៅសម្លាប់នៅហ្នឹង និយាយពីអារឿង ឡានហ្នឹងមកដល់ពីបស្រាប់តែមានម្នាក់រត់ ។

វីណាៈ អញ្ចឹង?

ស៊ីនៈ បាទ! ដែលវាចាប់មកមួយឡានហ្នឹង ហើយវាអន្លេងតែចូលទៅសញ្ញេរអញ្ចឹង មានម្នាក់ នោះរត់ ប្រហែលជានៅម៉ោង៨ ។

វីណាៈ ៨ភ្លឺ?

ស៊ីនៈ អត់ទេ ៨ល្ងាច ម្នាក់នោះលោតព្រះរត់ ហើយខ្ញុំនៅហ្នឹងវត្តហ្នឹងជិតនោះដែរ ចុះនៅ ម៉ោងប្រហែលជា៨អន្ទុយលេងនៅមុខវត្តនោះ ស្រាប់តែលឺលោតព្រះបានខ្ញុំដឹងថាអរ! អានេះចាប់យកទៅសម្លាប់តើ គឺគ្រាន់តែឡានឈប់ផក់លោតព្រះបណ្តោយ ហើយរត់ ហ្នឹងគឺរត់មកចំខ្ញុំ ហើយកាលហ្នឹងខ្ញុំនៅជាលោកនៅឡើយមិនទាន់សឹកទេ ហើយអាម្នាក់ ហ្នឹងគឺរត់ទៅតំរង់លោកបណ្តោយ ដល់តែរត់ទៅតំរង់លោក

និយាយពីក្មួយអើយវាបាញ់ នោះមហាបាញ់ហើយ ហើយគ្នា៣-៤ ៥នាក់ហើយសុទ្ធកាំភ្លើងដេញអាម្នាក់ដែលរត់ ហ្នឹងណា ហើយអាប៉ុន្មាននាក់នៅអង្គុយនៅក្នុងឡានហ្នឹងទៅ ហើយវាដេញតាមបាញ់មុខក្រោយឲ្យឡើងហុយដីសំពោង រត់ដេញអញ្ចឹងទៅ ហើយឡើងទៅអញ្ចឹង រត់ដេញដូចអាដែងស្ពុបនៅក្នុងទូរទស្សន៍អញ្ចឹងណា ។

សិដ្ឋ: ហើយរត់រួចដែលទេ?

ស៊ីន: ចាំមើលខ្ញុំនិយាយសិន ទៅស្គុយៗអញ្ចឹងហើយអាកាំភ្លើងវាបាញ់ជាប់មុខក្រោយៗ ហើយអាមនុស្សរត់ទៅឲ្យស្គុយៗ ហើយអត់មានត្រូវទេក្មួយ ហើយបើតាមអាកន្លែងដែល វាចុះរត់ហ្នឹងទៅដល់អាកន្លែងដែលវាស្លាប់នោះណាគឺជិតមួយគីឡូដី ។

វីណា: ទៅស្លាប់នៅឯណាវិញ.?

ស៊ីន: ដូចថាវារត់ទៅគឺដល់អាបឹងនោះណា ហើយត្រង់ហ្នឹងមានព្រៃវាច្រើននោះអញ្ចឹងវាចាល់ នៅត្រង់ហ្នឹងទៅ ហើយវាបាញ់ផាប់នៅហ្នឹង ដែលវាបាញ់បណ្ដើរពីនេះទៅគឺអត់មានត្រូវអីមួយគ្រាប់ទេ ហើយអាអ្នកដែលដេញនេះក៏រៀងយឺត ហើយអាអ្នកដែលដេញនោះក៏រៀងយឺត ហើយមនុស្សកាំភ្លើងក្លង់អញ្ចឹងរហូត ប៉ុនដែលទៅផាប់ហ្នឹងគឺវាទៅចាល់ហ្នឹង អាព្រៃដែលណែនប៉ែស ហើយយើងរត់អត់រួចចាល់អាហ្នឹងគេបាញ់ផាប់ហ្នូង ហើយ និយាយពីចំណែកពួកអានៅឡាននេះ រត់ទៅទាំងអស់ ។

រឿន: រត់ទៅណាដែរ?

ស៊ីន: ម្នាក់ក៏គ្មាននៅហ្នឹងដែរវារត់ដេញទាំងអស់ ដេញបាញ់អាម្នាក់ហ្នឹងទាំងអស់ ហើយអាអ្នកទោសហ្នឹងនៅអង្គុយនៅហ្នឹងទាំងអស់ ។

រឿន: ស្គុតពេក?

ស៊ីនៈ អញ្ចឹងបានតែថាមនុស្សនៅសម័យនោះអត់មានគិតអីឃើញសោះ ។

សិដ្ឋៈ ពួកអស់ហ្នឹងដឹងថាគេយកមកសម្លាប់ដែរឬក៏មិនដឹងទេ?

ស៊ីនៈ ទេ! ខ្ញុំគិតថាប្រហែលជាដឹងខ្លះឬក៏មិនដឹងទេ ដឹងហើយក៏មិនហ៊ានរត់ មិនដឹងជានៅពេលដែលវាទៅចាប់ហ្នឹងវានិយាយយ៉ាងម៉េចអីទេ បានជាឃើញហេតុការណ៍ដែលគេដេញបាញ់អានោះហើយនៅតែអត់រត់ទៀត ហើយខ្ញុំនៅមើលអញ្ចឹងដល់ពេលដែលវាបាញ់ ងាប់រួច ហើយដើរមកវិញហើយគឺមកកន្លែងឡានវាណាមកដល់វាស្រែកប្រាប់ ចុះខ្ញុំ នៅអង្គុយនៅមុខកុដ្ឋិ៣-៤អង្គនោះវាថាគេជគុណៗទៅកប់ខ្មោចទៅ ទៅកប់ខ្មោចទៅ ងាប់ហើយ ហើយវាបើកឡានមកវិញមកដល់ត្រង់ណេះសម្លាប់ចោលអស់ ។

វីណាៈ ហើយពូដើរទៅកប់ទេ?

ស៊ីនៈ ទៅកប់ជាមួយលោក ពីព្រោះនៅជិតវត្តដែរ ។

វីណាៈ ហើយចុះមានធ្វើបុណ្យធ្វើអីឲ្យដែលទេ?

ស៊ីនៈ អត់ទេ រកតែព្រះអាយូស នេះដោយសារតែជាលោកទេគឺចេះតែហ៊ានទៅៗ បើថាអ្នកស្រុកវិញមិនហ៊ានទៅមើលទៀតណាក្មួយ សូម្បីតែម៉ែឪក៏មិនហ៊ានទៅកប់ដែលណា ដូចថាវាបាញ់ម៉ែឪយើងងាប់អី

ហើយយើងជាកូននេះមិនហ៊ានទៅកប់ទៀតណានៅក្នុង សម័យនោះបានតែថាវាខ្លាចនោះគឺមហាខ្លាចហើយណា នៅក្នុងសម័យបីឆ្នាំហ្នឹងប្រុសៗ ហ្នឹងណាបើសឹងថាមានប្រហោងដីចុះទៅក្រោមវិញណា គឺហែកចូលទៅហ្នងបើសិនជាឃើញវាមកណាក្មួយ ។

វីណាៈ ចុះអាឡានហ្នឹងប៉ុន្មាន?

ស៊ីនៈ ឡានហ្នឹងវាច្រើនដែរ គឺសុទ្ធតែជាឡានទីសាន់ តួយ៉តាអីហ្នឹងអាអត់ត្របូលណា គឺភាគច្រើនវាដឹងតែអាហ្នឹងយកទៅសម្លាប់ ហើយភាគច្រើនគឺអត់មានដែលចងអីទេ ។

វីណាៈ ទទេរៗ ?

ស៊ីនៈ ប៉ា! សុទ្ធតែអញ្ចឹង ។

សិដ្ឋៈ នៅក្នុងឆ្នាំណាដែរ?

ស៊ីនៈ អាហ្នឹងចូល៧៦ហ្នឹងឯង ។

វីណាៈ កាលហ្នឹងពូអត់ទាន់សឹកទេ?

ស៊ីនៈ អត់ទាន់ទេ តែមិនយូរប៉ុន្មានទេប្រហែលជា៨-១០ថ្ងៃអីហ្នឹងគឺគេសឹកបណ្តោយទៅណា ។

វីណាៈ ចុះកាលហ្នឹងមានអ្នកភូមិអីយកចង្ហាន់អីទេប្រគេនដែលទេ?

ស៊ីនៈ អត់មានទេ ។

វីណាៈ ចុះបានអីឆាន់ទៅ?

ស៊ីនៈ អានេះគឺចេះតែមានស្បៀងលោកអីនៅសល់គឺចេះតែដោះស្រាយទៅណា បើថាចាំគេយកទៅប្រគេនអីគឺគ្មានទេក្មួយ គឺគេយកតែរស់រៀងៗខ្លួនទេ ពីព្រោះគេឃើញហេតុការណ៍អញ្ចឹងនោះ ដូចថាមួយថ្ងៃមួយមួយថ្ងៃពីរអីនោះគឺវាចេះតែដើរបាញ់ចោល នោះ ដូចថាយើងធ្វើជាទាហានដល់វាស្រាវជ្រាវដឹងថាយើងធ្វើជាទាហានអញ្ចឹង គឺទៅដល់វាបាញ់ចោលដាក់កណ្តាលផ្លូវអញ្ចឹងទៅ ដល់តែអ្នកស្រុកចេះតែឃើញអញ្ចឹងទៅគឺ ចេះតែភ័យព្រួយទាំងស្រីទាំងប្រុសអញ្ចឹងទៅណា ដល់អញ្ចឹងគឺគ្មានអ្នកណាយកចង្ហាន់ទៅ ប្រគេនលោកទេ គឺលោកដោយលោកប្រសក់ដោយប្រសក់នៅក្នុងសម័យហ្នឹង ។

វីណាៈ ហើយចុះនៅពេលដែលលាក់ខ្លួនហើយទៅសុំបាយគ្រួសារពូអី ហើយចុះឪពុកម្តាយពូអី នៅឯណាដែរ?

ស៊ីនៈ ឪពុកម្តាយខ្ញុំនៅក្រុមនៅនេះ នៅក្នុងកងណោះណា ប្រពន្ធខ្ញុំនៅកងខាងណោះទៅអញ្ចឹងខ្ញុំកាត់ ទៅរកខាងប្រពន្ធខ្ញុំ ។

វីណា: ចុះឈ្លបនៅក្នុងកងសម័យនោះអីអញ្ចឹង មានដឹងថាពូជាអ្នកលួចរត់អីដែលទេ?

ស៊ីន: អត់ដឹងទេ នៅពេលហ្នឹងគឺទាំងប្រុសទាំងស្រីអីមិនចង់ឲ្យគេឃើញមុខគ្នាទេ ដូចថាបើឃើញ វាជិះសេះមកអញ្ចឹង គឺសុខចិត្តពួននៅក្រោមផ្ទះណាក្អួយ ។

វីណា: ជិះសេះទៀត?

ស៊ីន: បាទ! សិទ្ធតែជាសេះ សហាវណាស់ ។

រឿន: ពេលដែលពូសឹកពីបួសហ្នឹង តើមានប្រជាជន១៧មេសាគេជម្លៀសមកពីភ្នំពេញឬនៅ?

ស៊ីន: មកហើយ ជម្លៀសមកហើយ ។

រឿន: ចុះនៅពេលដែលពូបួសមានមកឬបៅ?

ស៊ីន: អត់ទេ អត់ទាន់មានទេ នៅទេ ។

វីណា: ពូថាពេលដែលផ្លាស់អ្នកដឹកនាំនៅក្នុងភូមិនេះហើយ បានពូហ៊ានចូលមកភូមិវិញ?

ស៊ីន: បាទ! អាពេជឃាដហ្នឹងវានៅកន្លែងនេះសម្លាប់គេយូរទៅ អញ្ចឹងគេផ្លាស់ចេញណា ដល់ពេលដែលផ្លាស់វាចេញអញ្ចឹងទៅ ខ្ញុំចូលមក ។

វីណា: ម៉េចបានផ្លាស់ចេញពូ?

ស៊ីន: អើដូចថាវាផ្លាស់ពីកន្លែងមួយទៅកន្លែងមួយទៅណា គឺវាមិនឲ្យនៅកន្លែងហ្នឹងសាំទេ ។

វីណា: នៅឆ្នាំណា?

ស៊ីន: ឆ្នាំ៧៦ហ្នឹងឯង អាហ្នឹងគឺវាចាប់ផ្តើមស្រាវជ្រាវទាហានដែលនៅតាមភូមិមួយៗហ្នឹងណា ទំនាស់វាជាមួយទាហាននៅក្នុងភូមិមួយៗហ្នឹងឯង ។

វីណា: ខ្ញុំដូចជាអត់ទាន់យល់..ពូថាអ្នកដែលស្គាល់ពូអីហ្នឹងគឺគេជម្លៀសទៅ នៅកន្លែងផ្សេង ចុះអ្នកណាមកកាន់ជំនួសវិញ?

ស៊ីន: គេផ្លាស់អ្នកនោះផ្សេងដាក់មកនៅកន្លែងនេះវិញ ។

វីណា: មកពីស្រុកណាដែរ?

ស៊ីនៈ អាហ្នឹងគឺស្រេចតែគេដែរ ដូចថាគេនៅតាឃ្លាំងអីនៅស្អីងអីនៅតាគ្រាមអី គឺគេយកអាមេដែលនៅនេះទៅដាក់នៅនោះ ហើយគេយកអាមេនៅនោះមកដាក់នៅនេះ ប៉ាតគឺគេ ផ្ទេរគ្នាមកអញ្ចឹងណា គឺគេប្រើមិនឲ្យនៅសាំទេ គឺក្រែងវានៅហ្នឹងយូរៗទៅវាមានបងប្អូន

ខ្សែរអាអ្នកអស់ហ្នឹងទៅ ហើយវាអត់មានធ្វើអី អញ្ចឹងដកហ្អែងទៅដាក់នៅនោះទៅ ផ្លាស់ អាអ្នកផ្សេងមកដាក់នៅនេះវិញ ប៉ុនឈ្មោះគេគឺនៅតែមាន ដល់ពេលដែលអានោះមក

អញ្ចឹងមកគឺគេប្រគល់ឈ្មោះឲ្យទៅអាអ្នកថ្មីដែលមកកាន់កាប់ ឈ្មោះដែលត្រូវគេចាប់អ្នកណាអីដែលមានខ្លួនណា ។

វីណាៈ ចុះពូមានឈ្មោះនៅក្នុងហ្នឹងដែលទេ?

ស៊ីនៈ ខ្ញុំមាន សុទ្ធតែមានហើយ ប៉ុន្តពួកអាអស់នោះមុនហ្នឹងមកវាមានទៅស្គាល់យើងទេ គឺនៅ ពេលវាមកវាសួរតាមរយះប្រជាពលរដ្ឋបងប្អូនយើងនៅក្នុងភូមិអញ្ចឹង វាសួរតាមហ្នឹង ទៅ ហើយយើងរស់បានគឺដោយសារប្រជាពលរដ្ឋជាអ្នកគាំទ្រ គេថាគាត់ជាមនុស្សល្អ ឥឡូវនេះគាត់មិននៅនេះទេ គាត់ទៅនៅស្រុកគេផ្សេងបាត់ហើយន ដល់អញ្ចឹងអាអ្នកហ្នឹងវាមិនសូវជាចាប់អារម្មណ៍ដែរ អញ្ចឹងខ្ញុំបានរួចខ្លួនគឺដោយសារតែប្រជាពលរដ្ឋហ្នឹងឯងបើនិយាយឲ្យចំទៅ ប្រជាពលរដ្ឋនៅក្នុងភូមិគេគាំទ្រណា ។

វីណាៈ ចុះនៅពេលដែលពូត្រឡប់មកនៅក្នុងភូមិវិញ តើពូមានដំណឹងពីប្អូនពូដែលទេ?

ស៊ីនៈ អត់មានដឹងទេ គឺសូន្យរហូតមកដល់សព្វថ្ងៃនេះឯង ។

វីណាៈ ចុះពូថាប្អូនធ្លាប់ត្រឡប់មកដល់វិញម្ដងនោះ?

ស៊ីនៈ អាហ្នឹងចាំមើលខ្ញុំនិយាយ នៅពេលដែលគេដាក់អាវុធប្រើបនៅក្នុងឆ្នាំ៧៥ហ្នឹងណាគឺវាបានមកម្ដង បានប្រហែលជា៣-៤ថ្ងៃហ្នឹងឯង ។

វីណាៈ គេមកប្រាប់ថាម៉េចខ្លះទៅ?

ស៊ីនៈ ដូចថាគេមកលេងផង ពីព្រោះគេទៅ ណោះវា៣-៤ឆ្នាំហើយណា ទៅតាំងពីឆ្នាំ៧៣មក

ម៉្លេះ អញ្ចឹងវាមកលេងដើម្បីសួរសុខទុកអីទៅណា

ហើយគេមានបានមកលេងនៅយូរអី

ព្រោះនៅកាលនោះដូចថាក្បួនទ័ពគេមកមួយភ្លែតអញ្ចឹងទៅ

ហើយមេគេហៅទៅវិញទៅ

វីណាៈ មេគាត់ហ្នឹងពីណាគេទៅ?

ស៊ីនៈ មេគេហ្នឹងមិនដឹងជានរណាទេ មិនបានសួរដេញដោលទេ ប៉ុនមានគ្នាគេមកច្រើនដែរគឺមានគ្នា៥-៦នាក់ណា កាលហ្នឹងខ្ញុំសួរគេដែរថាហែ្ហងមកលេងប៉ុន្មានថ្ងៃ វាថាខ្ញុំមក២-៣ថ្ងៃអីគឺខ្ញុំទៅវិញហើយ ពីព្រោះមេខ្ញុំប្រញាប់ហៅទៅធ្វើការនៅជាយដែន ។

វីណាៈ ចុះពូមានសួរគាត់ថាធ្វើអីនៅឯណាឯណីអីទេពីមុនមកហ្នឹង?

ស៊ីនៈ អត់មានបានសួរនាំអីទេ

ព្រោះនៅពេលហ្នឹងសូម្បីតែបងប្អូនឯងមិនចង់ហ៊ាននិយាយទៀត ណាក្មួយ មិនចង់សួរដេញដោលទៀតណា វាមិនចង់ជឿទុកចិត្តថបងប្អូនឯងទៀតណា ។

វីណាៈ នៅពេលហ្នឹងពូទៅបួសហ្នុទៅ?

ស៊ីនៈ នៅពេលហ្នឹងខ្ញុំមិនទាន់ទៅបួសទេ បាទ!

នៅពេលដែលប្អូនខ្ញុំមកនេះគឺខ្ញុំមិនទាន់ទៅបួសទេ

វីណាៈ ហើយចុះអ្នកដែលមកជាមួយប្អូនពូហ្នឹង តើពូមានដែលស្គាល់ដែលទេ?

ស៊ីនៈ អត់ស្គាល់ទេ ប៉ុននៅក្មេងៗដូចគ្នាអញ្ចឹងណា ។

វីណាៈ កាលហ្នឹងប្អូនពូមានអាយុប៉ុន្មានហើយ?

ស៊ីនៈ ប្រហែលជានៅខ្ទង់២០-២១អីហ្នឹងហើយ ពីព្រោះកាលហ្នឹងខ្ញុំមានអាយុ២៣ ហើយវាប្រហែលជានៅខ្ទង់២១-២២អីហ្នឹង ពីព្រោះខ្ញុំបងវាមួយឆ្នាំណា ម្តាយខ្ញុំកូនច្រើននោះគឺមួយឆ្នាំមួយៗ ។

វីណាៈ អញ្ចឹងដល់ពេលពូត្រឡប់មកនៅភូមិវិញ តើពូនៅធ្វើអីដែរ?

ស៊ីនៈ ខ្ញុំអត់បានត្រឡប់មកនៅភូមិវិញទេ គឺខ្ញុំនៅណោះបណ្ដោយ ។

វីណាៈ ការហើយនៅនោះ?

ស៊ីនៈ ចាំ! នៅក្រុមនៅណោះគឺអត់មានមកនៅនេះទេ គឺទៅនៅខាងប្រពន្ធខ្ញុំនៅណោះទាល់តែ លែងមានសភាពការណ៍ចាប់ចងអីទៅ ហើយរៀងស្រួលទៅបានខ្ញុំត្រឡប់មកនៅនេះវិញ ហើយអត់មានធ្វើអីទេនៅក្នុងសម័យនោះ គឺនៅធ្វើតែប្រជាជនហ្នឹង នៅក្នុងរយះពេល បីឆ្នាំណាគឺអត់មានបានធ្វើអីទេ ។

វីណាៈ ធ្វើប្រជាជនហ្នឹង តើធ្វើការងារអីខ្លះទៅ?

ស៊ីនៈ ធ្វើស្រែអីហ្នឹង វាប្រើយើងធ្វើស្រែ ភ្ជួរ រាស់ ស្ទូង លើកប្រឡាយលើកទំនប់ គឺវាប្រើយើងមហាសែនប្រើហើយ បើយាយទៅ គឺវាប្រើយើងគឺមិនចាំថាយើងមានកំលាំងឬមិនមានកំលាំងអីទេ បើថាយើងមិនទៅទេឬក៏យើងឈឺមិនស្រួលខ្លួនអីគឺវាចោទថាយើង ជាខ្មាំងខុទាហរណ៍វាប្រើយើងឲ្យទៅត្រូស ហើយយើងថាអត់បានទៅទេខ្ញុំសុំសំរាកមួយ ព្រឹកអញ្ចឹងសូម្បីតែបបរក៏វាមិនឲ្យយើងដែរ តែមួយពេលក៏វាមិនឲ្យយើងហូបបបរដែរ

រឿនៈ កាលហ្នឹងពូរស់នៅជាមួយប្រពន្ធឬក៏នៅបែកគ្នា?

ស៊ីនៈ កាលហ្នឹងខ្ញុំនៅជាមួយប្រពន្ធ តែក្រោយមកបានវាបំបែកគ្នាដែលណា គឺវាឲ្យយើងទៅសមរភូមិមុខ ប្រពន្ធយើងនៅក្រោយហើយយើងទៅមុខអញ្ចឹងទៅ ។

វីណាៈ ទៅមុខហ្នឹងទៅណា?

ស៊ីនៈ មួយជួរដែលខ្ញុំទៅ គឺភាគច្រើននៅក្រហតដែលគេហៅថាក្រឡុងដុំ ទួលម្ទេស អាហ្នឹងសុទ្ធតែជាសមរភូមិក្ដៅហើយណា ។

សិដ្ឋៈ ស្រុកណាដែរ?

ស៊ីនៈ ស្រុកសង្កែយើងដែរ មិនជាឆ្ងាយទេប្រហែលជានៅ៣-៤គីឡូពីនេះទៅ ។

វីណាៈ នៅឆ្នាំណាដែរ ដែលគេបំបែកពូហ្នឹង?

ស៊ីនៈ ប្រហែលជាចូលឆ្នាំ៧៦ហ្នឹងឯង

វាឲ្យយើងទៅភ្ជួរស្រែអញ្ចឹងទៅឬក៏ឲ្យទៅលើកប្រឡាយ លើកទនប់អីទៅណា កាលហ្នឹងវាប្រើយើងឲ្យទៅលើកប្រឡាយលើកទំនប់ភាគច្រើន ហើយហ្នឹងឲ្យទៅភ្ជួរស្រែ ។

វីណាៈ ពូទៅតែម្នាក់ឯងឬក៏មានអ្នកស្រុកគេទៅដែរ?

ស៊ីនៈ ទៅគ្នាច្រើនដែរ ដូចថាទៅមួយដងមួយក្រុមទៅហើយមានគ្នា១០នាក់ទៅណា ជួនកាល វាឲ្យទៅ១០ថ្ងៃឬក៏កន្លះខែទៅណា ហើយវាផ្លាស់គ្នាមកអញ្ចឹងទៅ ហើយឲ្យ១០នាក់ទៅ ទៀត ។

វីណាៈ ហើយចុះប្រពន្ធពូនៅនេះធ្វើអីដែរ?

ស៊ីនៈ នៅនេះស្រីៗគេឲ្យធ្វើការស្រាលៗ នៅកិនស្រូវអីហ្នឹង ។

វីណាៈ ចុះពូកាលហ្នឹងមានកូនឬនៅ?

ស៊ីនៈ ខ្ញុំមិនទាន់មានកូនទេ ខ្ញុំទាល់តែជិតដាច់ឆ្នាំ៧៦បានខ្ញុំមានកូនមួយ គឺបានកូនបងហ្នឹងមួយ កូនស្រីណា តែកាលហ្នឹងវាប្រើខ្ញុំឲ្យទៅធ្វើស្រែប្រាំងនៅក្រហត គឺវាប្រើខ្ញុំឲ្យធាក់រហាត់ វាប្រើខ្ញុំឲ្យធាក់រហាត់មួយយប់ទើសភ្លឺ វាប្រើខ្ញុំ៤នាក់ឲ្យធាក់រហាត់ឲ្យបានទើសភ្លឺ រហាត់ ទឹកណាក្មួយ ដូចថាទឹកហូរអញ្ចឹងមកគេដាក់រហាត់ធាក់ឲ្យឡើងលើស្រែ ដល់អញ្ចឹងវាប្រើខ្ញុំមានគ្នា៤នាក់ឲ្យធាក់រហាត់មួយហ្នឹង ឲ្យបានទើសភ្លឺ ចាំមើលខ្ញុំនិយាយពីរឿងដែលវាឲ្យខ្ញុំធាក់រហាត់ហ្នឹង គឺថាវាធ្វើបាបខ្ញុំហ្នឹងគឺវាប្រល័យពូជសាសន៍ គឺវាឲ្យធាក់ម្តងពីរនាក់ រហាត់មួយណាក្មួយ ធាក់មួយដងពីរអ្នក នៅក្នុងមួយម៉ោងវាឲ្យផ្លាស់មួយដង ដូចថាខ្ញុំធាក់មួយម៉ោងអញ្ចឹងរួចខ្ញុំចុះ ឲ្យពីរអ្នកទៀតគេឡើងទៅធាក់មួយដង គឺផ្លាស់គ្នាឡើងចុះៗម្នាក់ម្តងៗ ប៉ុន្តែធ្វើម៉េចឲ្យបានទើសភ្លឺ ហើយវានៅយាមនៅហ្នឹងគ្នាវាមាន៥នាក់ កាំភ្លើង៥ដើម គឺវានៅដេកយាមយើង គឺវាឲ្យយើងធាក់ធ្វើម៉េចឲ្យបានទើសភ្លឺ មុនហ្នឹងវាឲ្យយើងធ្វើគឺវាដាក់បទបញ្ញារមួយ វាថាមិត្តឯងធាក់ធ្វើយ៉ាងម៉េចឲ្យបានដល់ភ្លឺ បើថា

ចង់ឈប់ក៏ឈប់ចុះគឺខ្ញុំអត់មានថាទេ

តែកុំឲ្យរហាត់ហ្នឹងឈប់គឺវាដាក់កំរិតយើងអញ្ចឹងណា

ហើយវានៅយាមនៅហ្នឹងដេកនៅហ្នឹង យើងដេកនៅហ្នឹងវាក៏ដេកនៅហ្នឹងដែរ ហើយ ក្មួយអើយនៅមុនដំបូងគឺបានមួយម៉ោងលើស បានយើងចុកជើងតែដល់ពេលយូរៗទៅ កន្លះម៉ោងទៅអត់រួច ដល់ទៅអត់រួចឈប់ ដល់ពេលយើងឈប់គឺវាបាញ់មួយគ្រាប់ដាំង ប៉ុន្តែវាអត់មានបាញ់យើងទេណា ។

វីណា: គេបាញ់ចោល?

ស៊ីន: ចាំ! វាថាមិត្តឯងឈប់ក៏ឈប់ទៅ តែរហាត់កុំឲ្យវាឈប់ ក៏នាំគ្នាធាក់ទៅទៀតទៅ ធាក់ មួយយប់ទើសភ្លឺ ហើយមានទៅដេកលក់អីក្មួយអើយ ដូចថាពីរអ្នកគេចុះមកអញ្ចឹងទៅ គឺយើងឡើងទៅធាក់ ហើយមិនទាន់បានប៉ុន្មានផងដល់ម៉ោងទៀតហើយ គឺដល់ម៉ោងឡើងទៅផ្លាស់ហើយយើងចុះមកទៀតហើយ ហើយយើងដេកទៀតហើយមិនទាន់បានទាំងលក់ផងគឺដល់ម៉ោងទៀតហើយ គឺថាគ្មានបានដេកទេ ហើយជើងនេះហើយណាក្មួយ យើងធាក់មួយយប់ទើសភ្លឺអាជើងនេះវាហើយណាក្មួយ ចុះវាអត់បានសំរាកសោះគឺថា បើធាក់មួយម៉ោងគឺជើងតែពេញមួយម៉ោងហ្នឹង ។

វីណា: ចុះធ្វើអញ្ចឹងរហូតរាល់ថ្ងៃហ្នឹង?

ស៊ីន: អត់ទេៗ! គឺបានតែមួយយប់គឺខ្ញុំរត់ចោលសមរភូមិហ្នឹង ។

វីណា: ចុះរត់ចោលម៉េចបានបើគេនៅយាមអញ្ចឹង?

ស៊ីន: ទេរត់ចោល ចុះនៅពេលថ្ងៃអីវាទៅបាយទៅអីគឺខ្ញុំរត់ចោលសមរភូមិ គឺខ្ញុំទ្រាំមិនបានទេ បើថាសម្លាប់ក៏សម្លាប់ទៅចុះ ចុះក្មួយអើយយើងទៅទ្រាំទ្រម៉េចបាន ។

រឿន: ចុះមានគេទៅតាមដែលអត់?

ស៊ីន: ចុះកាលនោះវាច្រើនច្របូកច្របល់ទៅ គឺអត់មានមកតាមដែលណា ។

វីណា: ចុះពូមានដែលស្គាល់អ្នកដែលមកយាមពូដែលអត់?

ស៊ីនៈ	អត់មានស្គាល់វាទេ វាមិនដឹងជាមកពីណាពីណី សុទ្ធតែជាក្មេងៗហើយខ្ទៅៗ ។

រឿនៈ	ចុះពូលាក់ប្រវត្តបានអញ្ចឹង តើគេមានដែលហៅពូទៅធ្វើជីវទស្សន៍អីដែលអត់?

ស៊ីនៈ	អត់ដែលទេ ។

រឿនៈ	គេអត់មានដែលហៅពូទៅធ្វើប្រវត្តិរូបអីទេ?

ស៊ីនៈ	អត់ទេ អត់មានទេ ហើយវាឲ្យយើងភ្លូវស្រែយប់ណាក្លួយ ។

សិដ្ឋៈ	អាហ្នឹងនៅពេលពូនិយាយថារត់ហ្នឹង?

ស៊ីនៈ	អត់ទេ អាហ្នឹងគឺនៅពេលក្រោយមកទៀត ដូចថាខ្ញុំមកដល់កងអញ្ចឹង ជួបកាលមេកងគេប្រើទៅទៀត គឺយើងរត់មកនៅកងរួចខ្លួនហើយណាតែជូនណាទៅគេប្រើយើងឲ្យទៅ ស្ទូងនៅហ្នង់ទៀត ទៅធ្វើនៅហ្នឹងទៀត ហើយយើងទៅទៀត ។

សិដ្ឋៈ	ចុះដូចថាកាលដែលពូនៅ នោះគឺពូមានសហករណ៍របស់ពូផ្សេង ហើយនៅពេលដែលពូរត់ មកនៅក្នុងកងនេះគឺគេមានសហករណ៍គេផ្សេង ចុះម៉េចគេព្រមទទួលពូឲ្យនៅទេ?

ស៊ីនៈ	ថាម៉េច!

សិដ្ឋៈ	ដូចថាពូនៅធ្វើរហាត់ទឹកហ្នឹងមិនពូនៅសហរកណ៍ពូផ្សេង ចុះពេលដែលពូមកនៅក្នុងភូមិ នេះសហករណ៍ជាមួយគ្នាដែរឬក៏មិនមែនទេ?

ស៊ីនៈ	អត់ទេ នៅផ្សេងគ្នា ។

សិដ្ឋៈ	ចុះពេលដែលពូមកអញ្ចឹង ប្រធានសហករណ៍គេមិនឆ្ងល់ថាហេតុអីបានជាពូមកនៅខាងនេះហើយគេមានសួរដែលអត់?

ស៊ីនៈ	គេសួរដែរក្លួយ តែខ្លះគេអនុគ្រោះដែលណា គឺគេដឹងយើងខ្លះដែរគឺដឹងថាយើងទៅហ្នឹងគឺវាវេទនាណា គឺមេកងខ្លះគេអត់គឹងរឹងទេ តែកុំតែគេប្រើហើយយើងមិនទៅហើយយើងប្រកែកអាហ្នឹងគឺយ៉ាប់ហើយ តែបើយើងទៅលត់ក្នុងសមរភូមិខ្លាំងហើយយើងនៅមិនរួចរត់មកវិញ ជួនណាគេអនុគ្រោះយើងដែរ គេអត់មានសួរដេញដោលយើងទេណា ។

វីណា៖ នៅនេះមានសហករណ៍ប៉ុន្មានតូ?

ស៊ីនៈ នៅនេះបើនិយាយទៅគឺមានសហករណ៍តែមួយទេ ។

វីណា៖ ឈ្មោះអីគេ?

ស៊ីនៈ គេដាក់ថាកន្ទឹអញ្ចឹង ។

វីណា៖ ហើយប្រធានសហករណ៍ឈ្មោះអីគេ?

ស៊ីនៈ ប្រធានឈ្មោះតាភ៌មៗ ។

វីណា៖ គាត់នៅរស់ទេ?

ស៊ីនៈ គាត់ស្លាប់ហើយ គឺគេលួចសម្លាប់

សម្លាប់នៅឆ្នាំយើង៧៩នេះហើយគឺនៅក្រោយរំដោះ នេះឯង ។

វីណា៖ អញ្ចឹង! ចុះអ្នកណាគេលួចសម្លាប់?

ស៊ីនៈ មិនដឹងជាអ្នកណាគេលួចសម្លាប់ទេ ពីព្រោះលួចនៅពេលយប់ណា ។

វីណា៖ ប្រហែលជាប្រជាជនទេហ្អី?

ស៊ីនៈ គេលួចបាញ់នៅពេលយប់ ។

វីណា៖ គាត់កាចពេកទេហ្អី?

ស៊ីនៈ ទេអាហ្នឹងគឺគេកាចហើយនៅក្នុងសម័យហ្នឹង មិនថាអ្នកណាក៏ដូចអ្នកណាដែរ ។

វីណា៖ គាត់មានដែលយកអ្នកអីទៅសម្លាប់ដែលទេ មានបញ្ជារយកអ្នកណាទៅសម្លាប់អី?

ស៊ីនៈ គឺគេមានបញ្ជារហើយ ។

វីណា៖ គាត់ជាអ្នកចេញបញ្ជារ?

ស៊ីនៈ បាទ! បើថាមេធំប្រហែលជាហ្នឹងហើយកាលហ្នឹងណា ដូចថាគេដឹកពីណាៗមកគឺគេចូលទៅសញ្ជោរនៅហ្នឹងឯង ទាល់តែអាមេហ្នឹងសញ្ជោររួចបានគេយកទៅសម្លាប់មេគឺឈ្មោះ ភ៌មហ្នឹងឯងកាលហ្នឹងនោះ ។

វីណា៖ ហើយចុះអ្នកដែលទៅយកហ្នឹងអ្នកណាគេ?

ស៊ីនៈ អ្នកដែលទៅចាប់ហ្នឹង!

វីណា៖ ចាស៎!

ស៊ីន៖ អត់ស្គាល់ទេ ។

វីណា៖ ចុះអ្នកដែលផ្លាស់មកនៅក្រោយហ្នឹង តើគេផ្លាស់មកនៅពេលណាពូ?

ស៊ីន៖ កាលហ្នឹងវាសម្លាប់យើងនៅនេះច្រើនហើយយូរដែរ បានវាផ្លាស់ថ្មីមកណា ។

វីណា៖ អាហ្នឹងពូថាផ្លាស់អ្នកចាស់ចេញហើយពូចូលមកភូមិហ្នឹងមែន ឬក៏នៅពេលក្រោយ?

ស៊ីន៖ ហ្ន៎! អានៅពេលហ្នឹងឯង ។

វីណា៖ ចុះគេមានដែលផ្លាស់ឬក៏ចាប់អ្នកចាស់ៗចេញដែលទេ?

ស៊ីន៖ មានដែលតើ ។

វីណា៖ នៅពេលណា?

ស៊ីន៖ នៅក្រោយមកជិតឆ្នាំ៧៨ហើយ ។

វីណា៖ អាហ្នឹងម៉េចពូ?

ស៊ីន៖ អាហ្នឹងគឺនៅខាងពាយ័ព្យគឺគេដកចេញហើយ គឺគេបញ្ចូលខាងពួកនិរតីមក កាលហ្នឹងមេកង ខាងខ្ញុំណា ខាងពាយ័ព្យណានៅឆ្នាំ៧៦-៧៧អីហ្នឹងគឺនៅខាងពាយ័ព្យទេ ដល់នៅពេលឆ្នាំ ៧៧-៧៨ហ្នឹងគឺផ្លាស់ខាងពួកនិរតីមក ។

វីណា៖ ចុះពួកអ្នកចាស់គេទៅណាវិញ?

ស៊ីន៖ អាហ្នឹងកាលហ្នឹងគឺខ្ញុំក្តាប់មិនទាន់បានដែរ គឺកាលហ្នឹងគេហៅមេកងៗទៅប្រជុំ គឺខាងនិរតី ហ្នឹងគេហៅមេកងដែលនៅកាន់កាប់ចាស់ហ្នឹងទៅប្រជុំ ទៅប្រជុំហ្នឹងគឺខ្ញុំក្តាប់បានមួយចំនួន ដែរ ស្រាប់តែមេកងចាស់ខ្លះដឹងខ្លួនគឺគាត់រត់ចេញ យើងឃើញគេរត់ចេញគឺយើងអត់ មានដឹងថាគេរត់ចេញអីយ៉ាងណាៗអីគឺយើងអត់មានដឹងទេ ប៉ុនដល់ពេលក្រោយមកបាន ដឹងថាពួកនិរតីហ្នឹងហៅមេកងចាស់ហ្នឹងទៅប្រជុំហ្នឹង គឺឲ្យតែពេលទៅគឺសម្លាប់ចោល ប៉ុន ដល់យើងតាមដានទៅដឹងហេតុការណ៍ច្បាស់ គឺពិតជាវាសម្លាប់មែន គឺពួកនិរតីសម្លាប់ មេកងពួកពាយ័ពចោលមែន ។

វីណាៈ ម៉េចបានជាពូដឹង?

ស៊ីនៈ ហើយពួកពាយ័ពដែលដឹងខ្លួនគឺបានរត់ចោលខ្លះ ។

វីណាៈ ចុះរត់ម៉េចរួចទៅ បើគេមកកាន់កាប់ហើយហ្នឹង?

ស៊ីនៈទេ! កាលហ្នឹងគឺមានគេរត់រួចទៅច្រើន គឺគេរត់ចូលទៅដល់ថៃណោះ ទៅស្រុកលើអញ្ចឹង ទៅហើយកាត់ចូលទៅថៃទៅ តែបើមេកងណាដែលអត់មានដឹងគឺងាប់ទាំងអស់ ។

វីណាៈ តែមេកងទេពូ! ចុះដូចជាប្រធានអីនោះ?

ស៊ីនៈ មេកងផង សហករណ៍ផងមេក្រុមផង ។

វីណាៈ ចុះមេឃុំនោះ?

ស៊ីនៈ មេឃុំផង គឺទាំងអស់ឲ្យតែជាអ្នកដែលនៅធ្វើការនៅក្នុងក្រុមហ្នឹងណា បើថាប្រជាជនគឺ អត់មានអីទេ ។

វីណាៈ គេហៅទៅប្រជុំហើយគេចាប់យកទៅឬក៏ម៉េច?

ស៊ីនៈ អត់ទេ! គឺគេហៅទៅប្រជុំនៅកន្លែងគេហ្នឹង ។

វីណាៈ កន្លែងគេនៅឯណា?

ស៊ីនៈ ដូចថាកន្លែងគេនៅបាត់ដំបងអញ្ចឹង គេហៅទៅកន្លែងគេទៅ គេហៅមេៗទាំងអស់ទៅ ប្រជុំនៅហ្នឹងណា ។

វីណាៈ ហើយបាត់ទៅ?

ស៊ីនៈ បាត់ទៅ ហើយមេងកងគេខ្លះគេរាងមិនទុកចិត្ត គេគេចចេញរួចខ្លួនទៅ តែភាគច្រើន ស្លាប់ច្រើនជាងរួចខ្លួន ។

វីណាៈ មងកងមេក្រុមអីហ្នឹង ពូមានស្គាល់អ្នកណាខ្លះដែរ?

ស៊ីនៈ មេងកងក្រុមនៅនេះគឺមានមេកងចាស់ណា គឺមានមេកង ឈឿក . មេកងឡឿន . មេកងភឿន......អីនៅឯកើតណោះអត់មានស្គាល់ទេ ទាល់តែនៅខាងនេះបានស្គាល់ អាហ្នឹងគឺនៅខាងពាយ័ពណាក្អួយ ប៊ុនស្លាប់អស់ហើយ មេកងឡឿននោះស្លាប់បាត់ហើយ

វាសម្លាប់ដែរណា ហើយហ្នឹងមេកងភឿននេះឈឿននេះមួយ ដែលគាត់ជាមេកងខ្ញុំដែរ គាត់នៅរស់ទេសព្វថ្ងៃនេះ ។

វីណា: គាត់នៅរស់?

ស៊ីន: បាទ! នៅលើណោះ ។

វីណា: កាលហ្នឹងគាត់រត់ហ្ន៎?

ស៊ីន: កាលហ្នឹងប្រហែលជាគាត់គេចរួចខ្លួន ហើយមេកងភឿនគាត់នៅរស់ដែរសព្វថ្ងៃ ។

វីណា: គាត់គេចដែរ?

ស៊ីន: គេចដែរ អញ្ចឹងឃើញនៅរស់ពីរដែលនៅកន្លែងនេះណា ដែលខ្ញុំបានឃើញណា ។

រឿន: ចុះឈ្មោះមឿកពូមានដែលលឺដែលទេ?

ស៊ីន: ឈ្មោះអី!

សិដ្ឋ: ឈ្មោះមឿក គាត់ជាប្រធានសហករណ៍នៅសង្កែ អរ!នៅកន្ទឺនេះ?

ស៊ីន: អត់ស្គាល់ទេ ។

វីណា: ប្រធានសហករណ៍មិញពូថាឈ្មោះអីដែរ ឈ្មោះឈឿក?

ស៊ីន: មិនមែនទេអាហ្នឹងប្រធានកងទេ ។

វីណា: ចុះប្រធានសហករណ៍នោះ?

ស៊ីន: កាលពីមុនឈ្មោះបងរ៉ម។ គាត់ជាប្រធានសហករណ៍ ហើយពីមុមេឃុំគឺតាម៉ង់ ដល់នៅពេលក្រោយមកទៀតដែលគេដូរស់មកថ្មីហ្នឹង មកពីខាងនិរតីហ្នឹងគឺខ្ញុំអត់មានស្គាល់ទេ គឺខ្ញុំស្គាល់តែមេកងខ្ញុំទេ ខាងនិរតីណាគឺមានតាសឿន តាណែន អាហ្នឹងមងកងខ្ញុំថ្មីដែលមកពីខាងនិរតីណា ខាងតាកែវគេមកហ្នឹង ។

វីណា: តាម៉ង់តារ៉ាមហ្នឹងនៅឯណាដែរ?

ស៊ីន: នៅខាងគាត់ហ្នឹង តាម៉ង់នេះគាត់នៅខាងកើតបាណន់នេះ គាត់ធ្វើជាប្រធានឃុំពីដើមនៅឆ្នាំ៧៥គាត់ធ្វើជាប្រធានឃុំ ។

វីណា: ចុះគាត់ម៉េចបានគាត់រួចខ្លួន?

ស៊ីនៈ អាហ្នឹងមិនដឹងដែរ មិនដឹងជាយ៉ាងម៉េចតែគាត់នៅសព្វថ្ងៃហ្នឹងណា ដូចជាតាឈឿក មេកឯខ្ញុំនេះគាត់នៅរស់សព្វថ្ងៃដែរហ្នឹង គាត់ហ្នឹងសហាវដែលណា ប៉ុនគាត់មិននៅនេះទេ គឺគាត់ទៅនៅស្រុកគេបាត់ហើយ ។

វីណាៈ ទៅនៅស្រុកកំណើតគាត់?

ស៊ីនៈ អត់ទេ ស្រុកកំណើតគាត់នៅណោះទេ នៅឯណាឯលើណោះទេ តែគាត់ទៅនៅភូមិគេណោះវិញណា ។

វីណាៈ នៅស្រុកអីឃុំអីវិញ?

ស៊ីនៈ នៅខាងថែងមានជ័យណោះ គាត់នៅហ្នឹង គាត់មិនមកនៅស្រុកកំណើតគាត់ទេ បើឲ្យគាត់មកនៅស្រុកកំណើតគាត់នៅកងចាស់គឺគាត់មិននៅទេ អញ្ចឹងបានជាគាត់ទៅនៅឆ្ងាយ ហ្នឹងណា ។

វីណាៈ អញ្ចឹងនៅក្នុងខេត្តហ្នឹងដែលតើ?

ស៊ីនៈ នៅហ្នឹងដែរហ្នឹង ជិះកង់អីខ្ញុំឃើញប៉ុន្មានដងដែរហ្នឹង តែអត់មានហ៊ានមើលមុខខ្ញុំទេ ។

វីណាៈ គាត់កាច?

ស៊ីនៈ គាត់ហ្នឹងកាចដែរហ្នឹងតាឈឿក នៅក្នុងកងហ្នឹងអ្នកណាក៏ថាកាចដែរ ព្រះអីនៅវត្តតាឈឿហ្នឹងគឺតាឈឿកហ្នឹងឯងជាអ្នកវៃទាំងអស់ ។

វីណាៈ គាត់វៃព្រះនៅវត្តណា?

ស៊ីនៈ វត្តវិហារហ្នឹងឯង តាឈឿកជាអ្នកវៃ គាត់នាំកុមារៗមកវៃមួយយប់អស់រលីងខ្ទេច ។

វីណាៈ គាត់មានអាយុប៉ុន្មានហើយ?

ស៊ីនៈ ឥឡូវបែបចូល៧០ ហើយមិនដឹង ។

រឿនៈ ចុះគាត់មានដែលចូលវត្តដែលទេ?

ស៊ីនៈ មិនដឹងទេ ក្តាប់មិនបានទេ ។

វីណាៈ នៅខេត្តនេះដែរ?

ស៊ីនៈ បើនិយាយទៅនៅក្នុងស្រុកបាណន់នេះដែរ តែគ្រាន់តែខុសឃុំទេណា ។

វីណា: នៅក្នុងឃុំអីគេ?

ស៊ីនៈ នៅឃុំថែងមានជ័យ ។

វីណា: ហើយគ្រួសារគាត់អីនៅហ្នឹងដែរ?

ស៊ីនៈ មិនដឹងជាស្លាប់បាត់ហើយមិនដឹង ប្រពន្ធបែបស្លាប់បាត់ហើយ ។

វីណា: គាត់នៅម្នាក់ឯងអញ្ចឹង?

ស៊ីនៈ មិនដឹង មិនដឹងជាយ៉ាងម៉េចអីអាហ្នឹងគឺខ្ញុំភ្លាប់មិនបានទេណា ពីមុនប្រពន្ធគាត់ឈឺហើយស្លាប់បាត់ហើយប្រពន្ធដើមនោះ ។

វីណា: គាត់មានធ្លាប់ចាប់អ្នកណាឬក៏ហៅអ្នកណាទៅដែលអត់ពូ?

ស៊ីនៈ វាមានដែរ គ្រាន់តែគេមិនចេញមុខណា គឺគេគ្រាន់តែបួញមាត់ចោលណា គ្រាន់តែមេគេដែលមកពីក្រោមៗណា ហើយគេគ្រាន់តែចង្អុលទៅហើយគេនៅតែផ្ទះគេទៅ គឺគេធ្វើ ធម្មតាទៅណា ម៉្លោះហើយអញ្ចឹងអ្នកខ្លះគេភ្លាប់មិនបានគេថាមនុស្សនេះល្អអញ្ចឹងទៅណា ប៉ុនមេកងនៅសម័យនោះគឺគ្មានអ្នកណាល្អទេក្មួយអើយ ។

វីណា: មេកង!

ស៊ីនៈ បាទ! សឹងថាមួយរយគឺមានតែមួយណា គឺអ្នកដែលមានចិត្តធម៌ច្រើននោះណា បើថាក្រៅពីហ្នឹងគឺគ្មានអ្នកណាគិតគូរអីទេមេកងនោះ ។

វីណា: ចុះពេលដែលពួកនិរតីចូលមកហ្នឹង គាត់រត់ទៅខាង....?

ស៊ីនៈ មេកងមិញហ្នឹង តាឈឿកមិញហ្នឹងគាត់បានជាប់គុកដែលតើ ។

វីណា: អញ្ចឹង!

ស៊ីនៈ ជាប់គុកដោយសារគ្នាវាហ្នឹងដែរហ្នឹង ។

វីណា: គ្នាណាទៅ?

ស៊ីនៈ ពួកគ្នាគេហ្នឹងណា មេធំៗជាមួយគ្នាហ្នឹងគឺគេចាប់យកទៅដាក់គុកជាងមួយឆ្នាំណោះ ។

វីណា: ពេលណាពូ?

ស៊ីនៈ ឆ្នាំ៧៦ - ៧៧ហ្នឹង ។

វីណាៈ អញ្ចឹង!

ស៊ីនៈ បាំ! វានៅពាក់កណ្ដាលឆ្នាំ៧៦ចូល៧៧ អញ្ចេះណាក្មួយមេកងហ្នឹងគាត់នៅក្ដាប់កងខ្ញុំហ្នឹងឯង កាលហ្នឹងក្រុមខាងរដ្ឋគេហ្នឹងគេមកដាក់កន្លែងនៅនោះ គេមានតាំងពីឡានគ្រឿងចក្រគ្រឿងអីណា ហើយគេមកធ្វើការនៅហ្នឹងហើយគេបាត់គោ បាត់ជ្រូកហ្នឹងណា អរ! អត់ទេគេបាត់ជ្រូក ហើយអាកូនចៅនៅខាងកងហ្នឹងវាចាប់ជ្រូកយកមកស៊ី វាដាក់អន្ទាក់ជ្រូកព្រៃតែវាមកជាប់អាជ្រូកស្រុកហ្នឹងណា ជាប់អាជ្រូករដ្ឋគេហ្នឹងណា ដល់តែអញ្ចឹងទៅនាំគ្នាយកមកស៊ី ហើយស៊ីហ្នឹងគឺស៊ីជាមួយហ្នឹងមេកងហ្នឹងឯង ដល់ពេល ហ្នឹងគេក្ដាប់បានថាខាងហ្នឹង ហើយពួកគេធ្វើការធំដែរគឺគេមានគ្នាគេ ដល់តែគេធ្វើការធំ ដាង ហើយគេស្រាវជ្រាវទៅថាអ្នកនេះស៊ីជ្រូកគេ ដល់គេដឹងថាអ្នកដាក់អន្ទាក់ហ្នឹង ដល់ តែគេសួរទៅ វាថាដាក់អន្ទាក់ជាប់មែន ជាប់មែនហើយគេសួរថាជ្រូកយកទៅណាទៅ វាថាស៊ីហើយ ហើយគេថាមានរាយការណ៍ទៅមេកងដែលទេ ថារាយការណ៍ឲ្យមេកង ដែរ តែមេកងហ្នឹងមកស៊ីដែរ ដល់អញ្ចឹងទៅគេមកចាប់ទាំងអាមេកងទាំងអាអ្នកស៊ីហ្នឹង យកទៅដាក់គុក ទៅដាក់នៅអាគុកគោដែលខ្ញុំនិយាយមិញហ្នឹងណា គេដាក់បានប្រហែល ជា៥ - ៦ខែហ្នឹងគេប្រលែងមកវិញ ។

វីណាៈ ប្រលែងមកវិញ គាត់នៅធ្វើជាមេកងដដែល?

ស៊ីនៈ អត់ទេ ធ្វើជាប្រជាជនធម្មតា ហើយស្គមដើរមិនចង់រួច យកទៅដាក់ធ្វើទារុណកម្មជាដូចគ្នា ។

រឿនៈ គាអីមិញ?

ស៊ីនៈ គាឈឿក ។

រឿនៈ ឥឡូវនៅរស់ដែលទេ?

ស៊ីនៈ នៅរស់ នៅឃុំបែងនេះ ដល់អញ្ចឹងទៅគាត់ដើរត្រេកៗមក ដើរមកហ្នឹងមិនចង់ដល់ផ្ទះទេ នៅពេលគាត់ចេញមកណា ចុះវាមិនឲ្យស៊ីបាយស៊ីទឹកអីឆ្អែតនោះ ។

វីណាៈ ហើយដល់ពេលដែលគាត់ចេញមកគាត់ធ្វើជាប្រជាជនធម្មតាវិញ?

ស៊ីនៈ ធម្មតា ។

វីណាៈ ធ្វើការអីដូចជាគេដូចឯងដែរ?

ស៊ីនៈ បាំ!ៗ ប៉ុននៅសព្វថ្ងៃនេះចាស់ហើយ បែបជាចូលដល់ចិតជាងហើយ បែបហួសផង មិនដឹង តែគាត់នៅជិះកង់ជិះអីបានដែរណា ។

វីណាៈ ចុះមេពីលើគាត់ទៀត ពីណាគេ?

ស៊ីនៈ អត់ទេ នៅកងនោះគឺគាត់ជាប្រធាន ។

វីណាៈ ចុះមេពីលើហ្នឹងដែលចាប់គាត់នោះ?

ស៊ីនៈ អាហ្នឹងមេធំគេ អាមេពេជឃាដដែលនៅបាណន់នោះ យើងអត់ស្គាល់ឈ្មោះគេទេ មេហ្នឹងមិនដឹងទេ ហើយអត់ស្គាល់មុខគេទៀតហ្នឹងណា គឺគេគ្រាន់តែបញ្ជារកូនចៅគេមកចាប់អញ្ចឹង ដូចថាអ្នកណាមួយអីគឺគេឲ្យតែឈ្មោះមក ហើយកូនចៅគេហ្នឹងមកចាប់ ។

វីណាៈ ចុះម៉េចបានជាមេហ្នឹងដឹងថា មេហ្នឹងលួចជ្រូកអី?

ស៊ីនៈ ចុះគេមានកូនចៅគេអីនៅហ្នឹងនោះ កូនចៅគេនៅធ្វើការនៅហ្នឹងដែរ ដល់អញ្ចឹងទៅគេ បាត់ជ្រូកគេ គេស្រាវជ្រាវណា ដល់តែស្រាវជ្រាវទៅវាប៉ះជាមួយហ្នឹងអាអ្នកដែលដាក់ អន្ទាក់ ដល់គេសួរទៅវាថាជាប់ជ្រូកស្រុកលើ ហើយគេសួរថាយកទៅណា វាថាយកស៊ី អស់ស៊ីជាមួយហ្នឹងមងកងអី បានជាគេចាប់ទាំងមេកង ចាប់ទាំងអាអ្នកដែលដាក់អន្ទាក់ អីយកទៅដាក់គុកទាំងអស់ ។

វីណាៈ គុកអី?

ស៊ីនៈ គេហៅថាគោ ដែលនៅខាងកើតបាណាន់នេះ នៅវត្តបាណាន់នេះ អាហ្នឹងគោហ្នឹងសំរាប់អ្នកទោសធ្វើទារុណកម្មអីគឺធ្វើនៅហ្នឹង

បើនិយាយទៅ នៅកន្លែងស្រុកបាណាន់នេះគឺចូល ទៅកន្លែងហ្នឹងទាំងអស់ ។

វីណាៈ អញ្ចឹងបានន័យថាមានមេកងអីដែរចូលទៅក្នុងគុកហ្នឹង មិនមែនមានតែប្រជាជនទេ?

ស៊ីនៈ អត់ទេគ្រប់ស្រទាប់ ឲ្យតែមានទោសគឺគេយកចូលទៅកន្លែងហ្នឹងទាំងអស់ អាហ្នឹងបើយើងនិយាយទៅគឺអ្នកមានទោសធុនកណ្តាលទេណា

បើថាទោសធ្ងន់គឺវាអត់មានដាក់គុក ទេ គឺវាបាញ់ចោលហើយ ។

វីណាៈ ហើយក្រៅពីតាឈឿកហ្នឹង

តើមានមេកងអី ក្រៅពីហ្នឹងហើយត្រូវគេចាប់យកទៅដាក់គុក អញ្ចឹងដែលអត់?

ស៊ីនៈ មាន ។

វីណាៈ ពីណាគេទៀត?

ស៊ីនៈ មេកងឡឿនហ្នឹងក៏គេចាប់យកទៅដាក់គុកនៅហ្នឹងដែរ ។

វីណាៈ គាត់ធ្វើខុសអីដែរ?

ស៊ីនៈ កាលហ្នឹងគាត់មិនមែនខុសអីនៅក្នុងកងទេ គឺគេស្រាវជ្រាវថាជាប់ក្បត់ ។

វីណាៈ នៅពេលណាពូ?

ស៊ីនៈ ជិតចូល៧៧ហ្នឹងហើយ តាមមើលគឺវាស៊ើបការណ៍ដឹងថាមេកងហ្នឹងប្រុងក្បត់ដល់អញ្ចឹង វាស៊ើបដឹងគឺវាចាប់យកទៅដាក់គុកសិន

ហើយក្រោយមកបានវាសម្លាប់ចោល ។

វីណាៈ ចុះមានអ្នកណាគេចូលទៅជាមួយគាត់ទៀត?

ស៊ីនៈ អ្នកដែលចូលរួមជាមួយអ្នកណាគេ ។

វីណាៈ អ្នកដែលចូលរួមក្បត់?

ស៊ីនៈ អរ! ប្រជាជន ។

វីណាៈ ហើយគាត់នៅជាមេក្រុមខាងអីដែរ មេកងអីគេដែរ?

ស៊ីនៈ មកក្នុងហ្នឹងដូចជាមកភូមិយើងសព្វថ្ងៃអញ្ចឹងដែរ គឺគេគ្នាប់ប្រជាជនមួយភូមិៗអញ្ចឹង ។

វីណាៈ ហើយគាត់នៅភូមិណា?

ស៊ីនៈ នេះនៅខាងកើតភូមិខ្ញុំនេះ គេហៅថាភូមិប៉ុសកន្ទី ដូចថានៅក្នុងមួយកងហ្នឹងមានមួយរយ ពីររយគ្រួសារអីហ្នឹង ។

វីណាៈ កាលហ្នឹងនិរតីគេចូលមកឬនៅពូ?

ស៊ីនៈ នៅទេ នៅពេលដែលគេចាប់ពួកអស់ហ្នឹងដាក់គុកហើយ បានពួកនិរតីអីគេចូលមក គឺវាចូលមកនៅចុងឆ្នាំ៧៧ហើយតាមមើលនោះ គឺនៅឆ្នាំ៧៧ហ្នឹង ។

វីណាៈ ចុះមានអ្នកផ្សេងទៀតដែលទេពូ?

ស៊ីនៈ មានតាវ៉ាម តាវ៉ាមហ្នឹងគាត់រួចខ្លួនដែរ តែនៅពេលដែលមកស្លាប់គឺមកស្លាប់នៅ៧៩នេះ ណែ គឺគេលួចសម្លាប់ហ្នឹងគឺនៅឆ្នាំ៨០គត់ហ្នឹងហើយ ។

រឿនៈ អញ្ចឹងនៅពេលដែលពួកនិរតីគេមកផ្លាស់ប្តូរហ្នឹង គឺខាងរបនាសម្ព័ន្ធគឺគេផ្លាស់ប្តូរហើយ?

ស៊ីនៈ គេផ្លាស់ប្តូរហើយ ។

វីណាៈ ប៉ុន្តែការងាររឺការហូបចុកអីរបស់ប្រជាជនធូរជាងមុនឬក៏យ៉ាងម៉េចដែរ?

ស៊ីនៈ ទេ! អត់ទេ គឺដដែលៗ ការរស់នៅជីវភាពរស់នៅហូបចុកអីគឺនៅដដែលៗហ្នឹង គឺមានសភាពធូរថយត្រង់ថាវាមិនសូវមានការសម្លាប់ប្រជាពលរដ្ឋណា គឺមានធូរថយនៅត្រង់ហ្នឹងបន្តិច តែអារឿងកម្មាភិបាលចាស់អីគឺវាមានគ្នាវាតាមដានស្រាវជ្រាវយកទៅសម្លាប់គ្នាវាទៀតណា តែបើរឿងប្រជាពលរដ្ឋដូចជានៅខាងខ្ញុំនេះគឺអត់មានសូវសម្លាប់ទេ គឺមានតែធ្វើស្រែហើយហ្នឹងនៅមួយកន្លែង តែនៅកន្លែងគេអីគឺខ្ញុំអត់មានដឹងទេ តែនៅពេលដែលនិរតីចូលមករឿងសម្លាប់អីគឺដូចជាអត់សូវមានទេ ។

វីណាៈ ចុះគុកនៅគោរនោះនៅតែមានបន្តទៀតដែលទេ?

ស៊ីនៈ នៅមាន..នៅមានបន្ត ។

សិដ្ឋៈ	ចុះប្រធានគុកហ្នឹងគេចាប់ដែលអត់ នៅពេលពួកនិរតីមក?

ស៊ីនៈ	អាហ្នឹងប្រហែលជាគេចាប់ដែរ ។

សិដ្ឋៈ	ចុះពេលដែលពួកនិរតីគេចូលមក ពួកគណៈឃុំគណៈភូមិអីគេយកទៅណាដែរ?

ស៊ីនៈ	អាហ្នឹងគេហៅទៅប្រជុំបាត់ៗអស់ទៅ មុនគេចូលមកដល់ភូមិគេហៅមេកងចាស់ មេកង ៣យ័ពហ្នឹងណាទៅប្រជុំអស់ តែបើត្រឹមមេកងមេក្រុមអីអាហ្នឹងមិនដឹងទេ តែបើត្រឹម មេឃុំគឺគេហៅទៅប្រជុំទាំងអស់ គេហៅទៅប្រជុំបាត់អស់រលីង ខ្ញុំឃើញអ្នកខ្លះគេដឹងខ្លួន ហើយគេគេចចេញ គេគេចចេញគឺរួច ហើយអ្នកដែលទៅទាំងអស់គឺបាត់ទាំងអស់ ហើយនៅកាលហ្នឹងបើខ្ញុំក្តាប់បានគឺវាសម្លាប់ ពេលដែលពួកនិរតីមកគឺគេហៅពួកចាស់ៗ ទៅសម្លាប់ចោលអស់ ។

សិដ្ឋៈ	ចុះគេអត់មានផ្លាស់ពួកគាត់អីទៅកន្លែងផ្សេងទេ?

ស៊ីនៈ	អត់មានទេ យកទៅសម្លាប់ចោលទាំងអស់ ។

វីណាៈ	ចុះពូមានដឹងថាមកពីហេតុអីបានជាមានការផ្លាស់ប្តូរអញ្ចឹងដែលទេ?

ស៊ីនៈ	ខ្ញុំអត់ដឹងដែរ មិនដឹងជាយ៉ាងម៉េចបានជានៅក្រោយមកមាននិរតីអីគេចូលមក អាហ្នឹងគឺ ខ្ញុំអត់មានដឹងដែរសភាពការណ៍ហ្នឹង ។

រឿនៈ	ចុះពូមានដឹងថាយ៉ាងម៉េច មានសភាពយ៉ាងម៉េចបានជាមានផ្លាស់ប្តូរពួកនិរតីមក?

ស៊ីនៈ	អាហ្នឹងក្តាប់អត់បានបង ក្តាប់បានគឺក្តាប់បាននៅពេលដែលវៀតណាមមកច្បាំងនៅបាត់ដំបងនេះ ។

រឿនៈ	អាហ្នឹងគឺនៅពេលឆ្នាំ៧៩ហើយហ្នឹង?

ស៊ីនៈ	បា៎!ៗ ចូល៧៩ហើយបានក្តាប់បាន ចុះកាលហ្នឹងសូម្បីតែវិទ្យុក៏វាមិនឲ្យមាន យើងនាំគ្នានិយាយ២-៣នាក់ក៏វាមិនឲ្យយើងនិយាយគ្នាដែរណា គឺវាបិតសិទ្ធយើងអស់រលីងទាំង អស់ ។

វីណាៈ	ចុះការរស់នៅហូបចុកអីយ៉ាងម៉េចដែរពូ?

ស៊ីនៈ	អាហ្នឹងមិនបាច់និយាយទេ ១០នាក់គេឲ្យបីកំប៉ុង របបដែលវាឲ្យយើងហូបគឺនៅក្នុង ១០នាក់គឺវាឲ្យយើងតែបីកំប៉ុងទេ ។

រឿនៈ	ចុះនៅតំបន់នេះគឺនៅក្នុងតំបន់១ទេពូកាលហ្នឹង?

ស៊ីនៈ	បាទ!ៗ នៅក្នុងតំបន់១ទេ ។

រឿនៈ	ចុះពូមានដែលបានឆ្លងទៅដល់តំបន់២-៣អីដែលទេ?

ស៊ីនៈ	កាលនោះខ្ញុំបានទៅដល់តំបន់៣ តំបន់៣ខ្ញុំបានទៅដល់ម្តង ខ្ញុំអញ្ចេះកុំអីក៏ខ្ញុំមិនបានទៅដល់ដែរពីព្រោះកាលហ្នឹងខ្ញុំបាត់គោនៅក្នុងកង ហើយខ្ញុំទៅរកគោណា គឺគេធ្វើសំបុត្រមួយដើម្បីឲ្យទៅរកគោ ទៅរកគោគឺទៅរកដល់តំបន់៣ ដល់ទៅឃើញនៅតំបន់៣ណោះ ហើយនៅតំបន់៣គឺវាដូចជាធូរស្រាលជាងនៅតំបន់១ ។

រឿនៈ	ចុះម៉េចដែរនៅខាងតំបន់៣នោះ?

ស៊ីនៈ	នៅតំបន់៣ បើតាមដែលខ្ញុំក្តាប់មើលគឺវាមានការហូបចុកខុសពីតំបន់ដែលខ្ញុំនៅនេះ គឺគេ មានបាយអីហូបត្រឹមត្រូវណា គឺគេមានម្ហូបអីបាយអីសំរាប់គេហូបគ្រប់គ្រាន់ដល់តែ នៅក្នុងតំបន់១នេះហូបបរ១០នាក់បីកំប៉ុង ហើយជួនណាដាច់អាបបរហ្នឹងទៀតណាក្លួយ ណា គឺវាឲ្យយើងហូប១០នាក់បីកំប៉ុងហ្នឹងឲ្យបានរៀងរាល់ថ្ងៃហ្នឹង គឺវាអត់បានទៀតណា គឺវាដាច់អាអង្ករបីកំប៉ុងហ្នឹងទៀត តែដាច់តែហូបទេណា តែអារឿងកំលាំងសំរាប់ធ្វើពល កម្មគឺវាឲ្យយើងធ្វើពលកម្ម គឺដាច់របបហូបហើយគឺវាមិនឲ្យយើងដាច់របបធ្វើការទេ គឺវាឲ្យយើងទៅធ្វើការទៀតណាក្លួយ អញ្ចឹងបានតែថាវាប្រើនេះគឺមិនមែនប្រើឲ្យយើងរស់ទេគឺវាប្រើយើងដើម្បីសម្លាប់យើងណា តែគ្រាន់តែថាយើងហ្នឹងវាមិនងាប់ តែបើសិនជាងាប់នោះគឺងាប់អស់ហើយ ។

វីណា៖ បងប្អូនពូក្រៅអីប្អូនរបស់ពូហើយហ្នឹងឪពុក ហ្នឹងបងដែលស្លាប់នៅក្នុងជំនាន់ លន់ នល់ ហ្នឹង តើមានអ្នកទៀតស្លាប់ដែរទេ?

ស៊ីន៖ អត់ទេ ។ បងប្អូនខ្ញុំបើស្លាប់ដោយសារប៉ុល ពតមានតែឪពុកខ្ញុំនិងប្អូនខ្ញុំមួយស្លាប់ដោយសារប៉ុល ពតអ្នាស់ ។ បងមួយនោះនៅពេលចុះទៅវើលន់ នល់ ។ ប្អូនមួយនោះស្លាប់ដោយរោគាទេ ។ អញ្ចឹងស្លាប់ដោយសារប៉ុល ពត៣ឆ្នាំនោះតែ ២ទេ ។

វីណា៖ ចុះពូ! ដល់ពេលពូមានបងប្អូនស្លាប់មានអីអញ្ចឹងអ្នាស់ ហើយពូយល់ឃើញម៉េចដែរ បើសិនជាអ្នកដែលធ្លាប់ធ្វើបាប ដូចជាអ្នកធ្លាប់ធ្វើបាបដូចតាឈៀកអីចឹង គាត់ធ្វើមេកង ជំនាន់ហ្នឹងអ្នាស់ហើយគាត់នៅរស់រហូតម៉ោដល់សព្វថ្ងៃ ពូជួបគាត់អីអញ្ចឹង ពូយល់ម៉េច ដែរចំពោះគាត់?

ស៊ីន៖ នេះវាអារឿងការខឹងវានៅតែមានម៉ង់ ប៉ុន្តែយើងមិនចង់យកអាកំហឹងទល់កំហល់គេសម្លាប់យើង យើងសម្លាប់គេ ។ វាចេះតែមានពៀរទៅវិញទៅម៉ោ ប៉ុនអាការខឹងអាការគុំ វានៅតែគុំចឹង ។ បើសិន ឧបមាថាបើនៅជិតវិញ ប្រហែលជាអាមោបាំងវាអត់គិតពីរឿងបាបពីរឿងបង់ទេ ។ ប្រហែលជាឈានទៅសម្លាប់គេវិញចោល ។ ប៉ុន្តែដល់នៅឆ្ងាយចឹង វារៀងណាយចិត្តដែរណាស់ ។ ប៉ុន្តែខ្ញុំចេះតែឮថ្នាក់ពួនិយាយថាគាត់ទោសខ្មែរក្រហមៗ មិនដឹងថាគាត់ថ្ងៃណាខែណាឆ្នាំណា ។ រហូតទាល់តែដល់យូរទៅៗ ម៉ាសេរីខ្ញុំងាប់អស់ទៅ គ្មានណាទាមទារកាត់ទោសទៀតទេ ។ វាអស់ហើយមានតែសេរីខ្ញុំហ្នឹងឯងដែលជួបឆ្លងកាត់ហ្នឹងណាប្អូន ។
បើសិនអស់ពីសេរីខ្ញុំទៅគ្មានណាគេ ទាមទារទេ ហើយក៏គ្មានកាត់ទោសទៀត ។

វីណា៖ ចឹងពូដឹងរឿងតុលាការហ្នឹងពីណាដែរពូ?

ស៊ីន៖ ខ្ញុំអត់បានស្តាប់បានអីទេក្មួយ ។ តុលាការកាត់ទោសណា ខ្ញុំស្តាប់មិនសូវបានដែរទេ ។

វីណា៖ ពូដឹងបានប៉ុណ្ណាដែរ?

ស៊ីនៈ អត់សូវដឹងដែរព្រោះខ្ញុំដាច់អាទូរទស្សន៍មុន លែងមានទូរទស្សន៍ស្តាប់ ។ ទូរទស្សន៍ឲ្យទៅកូនទៅ វាអត់ខ្លួនឯង ដាច់ទូរទស្សន៍ ។ សព្វថ្ងៃរៀងឈឺងបន្តិច ។

វីណាៈ ចុះអត់មានស្តាប់វិទ្យុអីទេ?

ស៊ីនៈ វិទ្យុក៏អត់ ។ សព្វថ្ងៃដូចស្ងាត់អស់ហើយ ២នាក់ប្តីប្រពន្ធ កូនចៅ ។

វីណាៈ ចុះពូដឹងបានត្រឹមណាដែរអញ្ចឹង?

ស៊ីនៈ ដឹង ពូថ្នាក់លើគេប្រកាសថាកាត់ទោសខ្មែរក្រហម១ ហើយថាលុយគេផ្តល់ឲ្យដែរប៉ុន្តែអារឿងកាត់ វាអត់ទាន់ឃើញកាត់ ។

វីណាៈ ចុះពូមានដឹងដំណឹងថាគេយកត្រឹមណាកាត់ទោសដែរទេ?

ស៊ីនៈ អត់ដឹង ។

វីណាៈ អឺ! ឆ្នាំនេះគេចាប់ផ្តើមបង្កើតឲ្យមានតុលាការហ្នឹងហើយណាពូ ។

ស៊ីនៈ បាទ១ ។

វីណាៈ ដូចប៉ុន្មានថ្ងៃមុននេះ ម៉ាអាទិត្យពីរអាទិត្យមុននេះ គេចាប់ផ្តើមស៊ើបអង្កេតអីអញ្ចឹងអីព្រោះតុលាការហ្នឹងគេបានតែងតាំងអង្គចៅក្រមអ្នកស៍ ។
ចៅក្រមខ្មែរហើយនិងចៅក្រម
បរទេសព្រោះយើងធ្វើការជាមួយអង្គការសហប្រជាជាតិអ្នកស៍ ។

ស៊ីនៈ បាទ ។

វីណាៈ តុលាការខ្មែរក្រហមហ្នឹងគឺរៀបចំដោយអង្គការសហប្រជាជាតិហើយនិងរដ្ឋាភិបាលយើង ។

ស៊ីនៈ បាទ១ ។

វីណាៈ ដល់ពេលអញ្ចឹងទៅចៅក្រមតែងតាំងទាំងពីរក្រុមហ្នឹងចូលធ្វើការហើយ ។
អ្នកដែលត្រូវ យកទៅកាត់ទោសហ្នឹង បើតាមច្បាប់គេថាយកអ្នកដែលជាមេដឹកនាំខ្ពស់ហើយនិងអ្នក ដែលទទួលខុសត្រូវខ្ពស់បំផុត ។

ស៊ីនៈ អ្នកយើងត្រូវយកកាត់ហ្នឹង?

វីណាៈ ចាស ។ អញ្ចឹងយើងអត់ដឹងថាអ្នកណាពិតប្រាកដទេ គ្រាន់តែមេដឹកនាំកំពូលៗនិងអ្នកដែលទទួលខុសត្រូវខ្ពស់ ។ អាហ្នឹងស្រាច់លើតុលាការគេអ្នកស៊ើបអង្កេត គេអ្នកវិនិច្ឆ័យ គេអ្នកគិតថាមួយណាដែលត្រូវយកទៅកាត់ទោស ។ ប៉ុន្តែចំពោះពូ ពូគិតម៉េចដែរបើសិន ជាគេយកតែអ្នកដែលជាមេដឹកនាំកំពូលៗនិងជាអ្នកដែលទទួលខុសត្រូវខ្ពស់អញ្ចឹង?

ស៊ីនៈ អានេះតាមយល់បើសិនកាត់អ្នកកំពូលៗក៏វាកាត់ទៅអត់សមស្រប អត់យុត្តិធម៌ទេ ។ ព្រោះអាអ្នកនោះបញ្ជាមែនប៉ុនអាអ្នកផ្ទាល់ ខ្ញុំថាអាអ្នកផ្ទាល់វាមានតាមស្រុកតាមខេត្ត វាមានផ្ទាល់ៗអាហ្នឹង ។

វីណាៈ ចុះបងគិតថាការចាប់ប្រជាជននៅក្នុងភូមិហើយនិងការសម្លាប់ហ្នឹង មានបញ្ជាពីលើម៉ោ ឬក៏ថាពួកខាងក្រោមនិងមេសហករណ៍អ្នកសម្រេចដោយខ្លួនឯង?

ស៊ីនៈ ខ្ញុំថាវាមានថ្នាក់លើបញ្ជាខ្លះហើយអ្នកទោសនេះវាហួសអាបទបញ្ជាខ្លះ ។ តាមមើលវាធ្វើតាមបទបញ្ជាដូចថាសម្លាប់មេៗមួយៗ ប៉ុន្តែអាអ្នកសម្លាប់ហ្នឹងវាមានលេងមួយៗ វាលេងអ្ហែងរាយ ។

វីណាៈ អញ្ចឹង?

ស៊ីនៈ បាទ ច្រើនលើសអាផែនការដែលដាក់ម៉ោ ។ អាហ្នឹងតាមមើលអនុវត្តិលើសផែនការទៀតណាស់ ។ បាទ ខ្ញុំយល់ថាអញ្ចឹងម៉ង់ ។

វីណាៈ ចំពោះតុលាការនៅថ្ងៃខាងមុខហ្នឹងគេកាត់ទោសតែមេដឹកនាំកំពូលៗទេ ។ អ្នកដែលនៅសហករណ៍ខាងក្រោម មេភូមិគណៈឃុំ គេអត់កាត់ទោសទេ ។ ចំពោះពូផ្ទាល់គិតថាតុលាការហ្នឹងវាសមស្របសម្រាប់ពូដែរអត់ ពូ? គ្រប់គ្រាន់សម្រាប់ពូដែរអត់?

ស៊ីនៈ វាសឹងថាគ្រប់គ្រាន់ទៅចុះណា បើកាត់ទោសអ្នកកំពូលៗអ្ហាស៎ ។ ខ្ញុំថាវាគ្រប់គ្រាន់ទៅចុះ ខ្ញុំវាឯកភាពដែរ ។ វាមានអ្នកបញ្ជាពីលើ ចឹងអ្ហេស៎! បានថ្នាក់ក្រោមវាធ្វើ ។

វីណាៈ ចាស ។

ស៊ីនៈ ចឹង បើថ្នាក់លើឯកភាពថាកាត់កំពូល ល្អហើយ ។ ទាន់ខ្ញុំនៅឃើញអ្ហាស៎! ខ្ញុំចង់ឃើញ អាណាខ្លះដែលជាវាជាអ្នកមេដឹកនាំពេជ្ឈឃាតសម្លាប់ប្រជាពលរដ្ឋអស់រាប់លាន ។

វីណាៈ ចាស ។

ស៊ីនៈ បើតាមមើលទៅ ខ្ញុំពូថាអ្នកធំច្បាស់ជាផគេគឺខៀវ សំផន និងប៉ុល ពត ។ អៀង សារី នួន ជា តាម៉ុក មេធំៗ ។

វីណាៈ ពូដឹងនៅពេលសម័យខ្មែរក្រហម ឬក៏ដឹងក្រោយពេលបែកម៉ោហើយ?

ស៊ីនៈ អត់ទេ ។ ដឹងតាំងពីយើងចិតបី ចិតបួនអ្ហោះ ។ ដឹងតាំងពីហ្នឹងម៉ោ ។ សំខាន់ខៀវ សំផនដឹងតាំងពីចិត្តមួយ ចិត្តពីរអ្ហោះ ។

វីណាៈ ពូស្គាល់?

ស៊ីនៈ បាទៗ ។ បើប៉ុល ពតក្រោយម៉ោទេ ។ ប៉ុល ពតដឹងឆ្នាំ៧៥ ហើយទេ ។

វីណាៈ ចាស ។

ស៊ីនៈ តាម៉ុក នួន ជាទើបដឹងនៅប៉ែតបី ប៉ែតបួន ។ បើដំបូងខៀវ សំផនដែលខ្ញុំដឹងអ្ហាស៎ អ្នកមេដឹកនាំធំអ្ហាស៎ ។

វីណាៈ ចាស ។ ចុះពូ ដូចនៅភូមិហ្នឹងអញ្ចឹងគេដឹងរឿងតុលាការហ្នឹងច្រើនអ្ហេ៎ពូ?

ស៊ីនៈ ប្រហែលជាដឹងខ្លះហើយព្រោះអីគេមានវិទ្យុស្តាប់ ។ ខ្ញុំវាគ្មានវិទ្យុស្តាប់ យូរខែហើយ ចង់កន្លះឆ្នាំហើយ ។ ទូរទស្សក៏អត់ វិទ្យុក៏អត់ ។ ខ្ញុំចែកឲ្យកូន...ដល់អញ្ចឹង វាដាច់ព័ត៌មាន ។ សូម្បីតែកូនវិទ្យុក៏អត់មានស្តាប់ដែរ ។ ពីមុនខ្ញុំស្តាប់ខ្លះព័ត៌មានតាម វិទ្យុ តាមទូរទស្សន៍អ្ហាស៎ ឥឡូវវាដាច់ មិនដឹងគេកែប្រែយ៉ាងម៉េច ដល់ដំណាក់ កាលណាអត់ដឹងទេ ។

វីណាៈ ចុះពូយល់ថាចាស់ៗដែលដឹងអីច្រើន បើសិនជាពេលមានតុលាការទៅ ពួកគាត់អាចទៅ ជាសាក្សីសម្រាប់ឆ្លើយចំពោះមុខតុលាការចំពោះរឿងរ៉ាវដែលកើតឡើងនៅសម័យនេ វះ បានដែរពូ?

ស៊ីនៈ ប្រហែលជាមានហើយក្មួយ ។

វីណា: ប្រហែលជាមាន?

ស៊ីនៈ ប្រហែលជាមាន ព្រោះគេមានការលំបាកឆ្ងងកាត់ក្នុងសម័យហ្នឹងអ្ហាស៎ ។ អញ្ចឹងគេអាច ហ៊ានធ្វើសាក្សីហើយ ។

វីណា: ចុះពូអត់យល់ថាគាត់ខ្លាចគាត់អត់ហ៊ានអីអ្ហេ?

ស៊ីនៈអត់មានខ្លាចអីទេអាហ្នឹង! បើនិយាយត្រង់អាហ្នឹងការពិតអ្ហាស៎ ។ ការពិតអត់មាន ខ្លាចទេ ។

វីណា: អញ្ចឹងបើសិនជាតុលាការគេដូចថាគេចង់រកសាក្សី ឬចង់អញ្ជើញប្រជាជនយើងអ្នកដឹង រឿងរ៉ាវអស់ហ្នឹងយកទៅធ្វើជាសាក្សី គាត់ព្រមទៅអត់?

ស៊ីនៈ មិនដឹងថាយ៉ាងម៉េចដែរអាហ្នឹង មិនអាចដឹងដែរ ។

វីណា: ចុះចំពោះពូផ្ទាល់?

ស៊ីនៈ ជួនកាលគេខ្លះគេថាគេមិនទៅ គេថាគេអត់លុយកាក់អីមិនដឹងអ្ហេណាស់ ។ ប៉ុនចំពោះខ្ញុំ ផ្ទាល់ ខ្ញុំមិនខ្លាចទេអារឿងធ្វើសាក្សី ។ ព្រោះហេតុការណ៍ហ្នឹងវាជាក់ស្តែង ។

វីណា: ឧទាហរណ៍ថាឥឡូវក្នុងតុលាការគេចោទទៅលើមេដឹកនាំណាមួយ គេចោទថាក្នុងសម័យ ខ្មែរក្រហមហ្នឹងមានការបាញ់សម្លាប់ទាហានលន់ នល់ឬក៏បាញ់សម្លាប់ប្រជាជនស្លូតត្រង់ ហើយមេខ្មែរក្រហមរូបនោះឆ្លើយថាអត់មានទេ ។ ដូចករណីពូធ្លាប់ឃើញគេយកអតីតៈ ទាហានលន់ នល់ មន្ត្រីរាជការទៅសម្លាប់អីចឹងអ្ហាស៎ ។ ពូអាចទៅធ្វើជាសាក្សីក្នុងថ្ងៃហ្នឹង បានអត់?

ស៊ីនៈ ធ្វើបាទ ។

វីណា: ពូអត់ខ្លាចទេ?

ស៊ីនៈ អត់ខ្លាច! មិនអាចខ្លាចបានទេ ។ បើឪពុកខ្ញុំស្លាប់ដោយសារហ្នឹង ប្អូនខ្ញុំស្លាប់ដោយសារ ហ្នឹង ។ ខ្ញុំអត់មានខ្លាចអីទេ ។

វីណា: ចុះពូយល់ថាអ្នកផ្សេងទៀត?

ស៊ីនៈ អ្នកផ្សេងទៀត យើងមិនអាចប្រាប់គេបានដែរ ។ ជួនកាលគេមិនទៅ គេថាគេមិនដឹងគេមិនព្រូ ខ្ញុំមិនដឹងទេណាស់ ។

វីណាៈ ចុះពូគិតថាអីទៅជាបញ្ហាដែលគេមិនទៅ ?

ស៊ីនៈ ជួនកាលអញ្ចេះដែរ ជួនកាលទៅ យើងត្រូវប្រើលុយកាក់អីចឹងទៅណាស់ ។

វីណាៈ អូ!

ស៊ីនៈ ជួនកាលគ្មានអត់លុយអត់កាក់ ជួនកាលគេមិនទៅ ។ វាមិនដឹងត្រង់ហ្នឹងណាស់ ។

វីណាៈ ចុះបញ្ហាសន្តិសុខវិញ ជាបញ្ហាចោទដែរអត់?

ស៊ីនៈ បាទ បញ្ហាសន្តិសុខនេះជាបញ្ហាចោទមួយដែរ ។

វីណាៈ ចឹង បញ្ហាទី១គឺបញ្ហាលុយកាក់ ខាតរកស៊ីអីអញ្ចឹង ។

ស៊ីនៈ ហ្នឹងហើយទៅ ធ្វើដំណើរតាមផ្លូវចឹងណាស់ ។ ហូបចុកអីចឹងទៅវាមានការខ្វះខាតណាស់ ។ ដល់ឲ្យទៅ ជួនកាលគេមិនទៅក៏មានដែរ ។

វីណាៈ អញ្ចឹង ឧទាហរណ៍បើអញ្ចេះវិញពូ បើសិនជាគេអញ្ជើញពូទៅគេប៉ះប៉ូវឲ្យពូវិញអីអញ្ចឹង អ្ហាស៎ ។ គេប៉ះប៉ូវឲ្យពូអញ្ចឹង ពូអាចទៅ អ្ហេស៎មើលទៅ ?

ស៊ីនៈ បាទ អាហ្នឹងទាល់តែអញ្ចឹងដែរ ។ យើងជួយឧបត្ថម្ភដែរ យើងទៅខាតពេលវេលាចឹងណាស់ ។ ខាតការងារអីអញ្ចឹង ។

វីណាៈ ឲ្យគេការពារសន្តិសុខយើង?

ស៊ីនៈ បានឲ្យគេការពារសន្តិសុខដែរ វាអាយុជីវិតមួយដែរអាហ្នឹង ។

វីណាៈ ពូគិតថាតុលាការដែលបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ហ្នឹងអ្ហាស៎ អាចរកយុត្តិធម៌ជូនប្រជាជនទូទាំងប្រទេសខ្មែរយើងបានដែរអត់? អាហ្នឹងចំពោះពូគិតថាតុលាការយ៉ាងម៉េច?

ស៊ីនៈ ប៉ុន្តែខ្ញុំ គាមខ្ញុំយល់ទេ វាអាចរកយុត្តិធម៌ជូនប្រជាពលរដ្ឋបានអ្នាស់ បើថាមានកាត់ទោស ។ បើថាមិនកាត់ទោសអាហ្នឹងវាមិនដឹងទេ បើថាកាត់អាហ្នឹងអាចរកយុត្តិធម៌ជូនប្រជាជនបាន ។

វីណាៈ ដូច្នេះបើសិនជាគេរកឃើញកំហុសមេដឹកនាំថ្នាក់កំពូលៗខ្មែរក្រហមហ្នឹងអ្នាស់ ថាពួកគាត់ មានកំហុសដែលធ្វើឲ្យប្រជាជនមានការហូបមិនគ្រប់គ្រាន់ មានការសម្លាប់ក្នុងពេលដែល គាត់កាន់អំណាចហ្នឹងអ្នាស់ ហើយពេលដែលគេកាត់ទោសទៅ ចំពោះពូផ្ទាល់ ពូចង់ឲ្យគេដាក់ទោសគាត់កម្រិតណាដែរ?

ស៊ីនៈ អានេះទៅតាមទោសដែលគាត់ប្រព្រឹត្តពេលដែលគាត់ធ្វើ ។ ដូចថាគាត់ត្រូវជាប់គុកប៉ុន្មាន ឆ្នាំអាហ្នឹងទៅតាមទោសគាត់ ។

វីណាៈ ទៅតាមតុលាការសម្រេចទៅ?

ស៊ីនៈ បាទ ទៅតាមដែលគេសម្រេចទៅ ។

វីណាៈ

អញ្ចឹងពូដូចថាបញ្ហាដែលអាចកើតឡើងចំពោះជនរងគ្រោះយើងដែលគាត់មិនហ៊ានទៅធ្វើ សាក្សីអ្នាស់ ដោយសារបញ្ហាខុះខាតជីវភាព ។

ស៊ីនៈ សន្តិសុខ អ្នកហ្នឹងទៅបានស្រួលដែរហើយទៅប្រាក់ធ្វើដំណើរទៅម៉ោ ។ ការខាតពេលវេលាអញ្ចឹង ។ អារឿងសន្តិសុខហ្នឹងវាសំខាន់ ។

វីណាៈ សន្តិសុខហ្នឹងម៉េច ពូចង់សំដៅទៅលើរឿងអីដែរ?

ស៊ីនៈ ដូចថាយើងទៅធ្វើសាក្សី ត្រូវមានកងកម្លាំងប៉ូលីសដូចកងរាជអាវុធការពារពេលដែលយើងទៅ ។ ពេលដែលយើងស្នាក់នៅកន្លែងអីចឹង ។

វីណាៈ ពូថាបើតាមពូគិតទៅរឿងបញ្ហាសន្តិសុខ ខាងណាម៉ោធ្វើអីដល់សាក្សីហ្នឹង ឬក៏យ៉ាងម៉េច?

ស៊ីនៈ	អានេះវាមិនថាទៅលើខាងណាទេ  ប៉ុន្តែយើងការពារអ្នកស្រី ។  វាត្រូវតែការពារដែរ សាក្សីមិនធម្មតាទេ ។

វីណាៈ	អញ្ចឹងបញ្ហាគឺពីរហ្នឹង ។ អញ្ចឹងពូមានអីចង់បន្ថែមទៀតទេ?

ស៊ីនៈ	ខ្ញុំចង់បន្ថែមថាធ្វើយ៉ាងណាឲ្យថ្នាក់លើរៀបចំឲ្យបានឆាប់ ។

វីណាៈ	ឲ្យបានឆាប់អ្ហ៎?

ស៊ីនៈ	បាទ  ព្រោះសំណូមពរប្រជាពលរដ្ឋភាគច្រើនគេទាមទារណាស់ ។  ប្រកាសថាកាត់ទោសៗប៉ុន្មានឆ្នាំម៉ោហើយ ។

វីណាៈ  បើខាងគេរៀបចំឲ្យពូទៅមើលកន្លែងកាត់ទោសហ្នឹង កន្លែងសារៈមន្ទីរទួលស្លែង កន្លែងដាក់ឃុំខ្លួនមនុស្សអីចឹងអ្នកស្រី ។ សួរចម្លល់ពីបញ្ហាតុលាការហេតុអីបានយូរ ហេតុអីបានទើបចាប់ផ្ដើមចឹងអ្នកស្រី ពូចង់ទៅដែរអត់?

ស៊ីនៈ	ដូចខ្ញុំនិយាយចឹង ដូចថាមានការផ្ដល់លុយកាក់ទៅម៉ោអី ខាតពេលវេលាចឹងអ្នកស្រី ។

វីណាៈ	អញ្ចឹង បើសិនមានគេផ្ដល់ចឹង ពូចង់ទៅមើលដែរអត់?

ស៊ីនៈ	បាទ ទៅ ។ ចង់ទៅមើលដែរ ។

វីណាៈ	ចុះពូមានអីចង់បន្ថែមទៀតដែរអត់ ពួកខ្ញុំដូចអស់អីសួរហើយ ។

ស៊ីនៈ	ខ្ញុំដូចអស់ដែរហើយ  គ្រាន់តែសំណូមពរប៉ុណ្ណឹង ។  ឲ្យថ្នាក់លើរៀបចំទៅណាស់ជាបន្ទាន់ណាស់ ។ សព្វថ្ងៃមើលមិនឃើញទេម្នាក់ៗអាយុហាហុកហើយហ្នឹង ដល់ចេះតែកាត់ៗ  ចូលដល់ចិតមិនទាន់បានកាត់ផង ។  អ្នកខ្លះគ្នាស្លាប់បាត់ទៅ  មិនដឹងថាគេកាត់ទោសខ្មែរក្រហមឲ្យឬមិនឲ្យ ។  កាត់ឬមិនកាត់  ចឹងណាស់ ។  អ្នកដែលជួបវិបត្តិដូចខ្ញុំវាគ្រោះថ្នាក់ច្រើនសំខាន់ដោយសាររបបពាឆ្នាំហ្នឹង ។  អញ្ចឹង  បានខ្ញុំចង់ដឹងដែរបុគ្គលណាដែលជាអ្នកនាំអាតសម្លាប់ប្រជាពលរដ្ឋ ។  ខ្ញុំចង់ដឹងដែរណាស់ ។  ខ្ញុំហាជាងហើយខ្ញុំចង់ដឹងដែរ ។

វីណាៈ	សព្វថ្ងៃពូមានដឹងថាមេដឹកនាំខ្មែរក្រហមមានអ្នកណាខ្លះ?

ស៊ីនៈ ខ្ញុំស្តាប់អត់បានច្បាស់ដែរ ។ ខ្ញុំដឹងថានៅ ខៀវ សំផន នៅតាម៉ុក ។ តាម៉ុកឮថាដូចស្លាប់ មិនដឹងពិតមិនពិតទេ ។

វីណាៈ តាម៉ុកគាត់នៅរស់សព្វថ្ងៃ ។

ស៊ីនៈ ប៉ុល ពត ។

វីណាៈ ប៉ុល ពតស្លាប់ហើយ ។

ស៊ីនៈ បាទ ប៉ុល ពតស្លាប់ហើយ ។ ចុះអៀង សារី?

វីណាៈ មានអ្នកណាគេទៀត?

ស៊ីនៈ នួន ជា ។ តែប៉ុណ្ណឹងឯង ។

វីណាៈ ពូខ្ញុំចង់សួរបន្ថែមពេលវៀតណាមចូល៧៩អ្នកស្រុកពូ ព្រោះពូរៀបរាប់ម៉ោដល់កន្លែងហ្នឹង ខ្ញុំភ្លេចសួរ ។ ពេលហ្នឹងពូនៅណា ហើយធ្វើអីដែរ ពេលវៀតណាមចូល៧៩?

ស៊ីនៈ ៧៩ខ្ញុំមិនទាន់នៅនេះទេ នៅបាត់ដំបង ។ ខ្ញុំរត់ទៅនៅហ្នឹងអ្នកស្រុក ។ ខ្ញុំរត់នាំកូននាំចៅទៅ នៅ ។ គិតទៅទាំងអស់គ្នា អត់មានអ្នកណានៅនេះទេ ។ ហ្នឹងហើយ៧៩ដែលវៀតណាម រំដោះបាទ ។ រំដោះពីប ប្រជាជនថយម៉ោនៅហ្នឹងទាំងអស់ ។

វីណាៈ អញ្ចឹង បានន័យថាអត់មានអ្នកណានៅហ្នឹងទេ?

ស៊ីនៈ បាទ អត់ទាន់មានទេ ។ រយៈពេលខ្លះម៉ាខែ បានប្រជាជនឡើងម៉ោខ្លះអ្នកស្រុក ។ រាយមួយៗទេ ។ អ្នកណាគេហ៊ានគេម៉ោមុន ណាអត់ហ៊ានគេនៅហ្នោះនៅឡើយទេណាស់! ព្រោះកន្លែងនេះមានវៀតណាមនៅខ្លះ ។ ចឹង៧៩ហ្នឹងនៅហ្នោះទាំងអស់គ្នា ក្រោយម៉ោ១ខែ ឬ២ខែបានឡើងម៉ោខ្លះ ។

វីណាៈ ចុះវៀតណាមឡើងម៉ោតាមផ្លូវណាពូ?

ស៊ីនៈ តាមផ្លូវនេះឯង!

វីណាៈ ចឹងម៉ោពីក្រោមម៉ោវិញ?

ស៊ីនៈ បាទ ម៉ោពីក្រោមម៉ោវិញដេញឡើងទៅលើ ។

វីណា៖ ចឹងម៉ោដេញពួកខ្មែរក្រហមទៅណាវិញ?

ស៊ីន៖ ដេញឡើងទៅលើ ។

វីណា៖ ចូលព្រៃ?

ស៊ីន៖ បាទ ចូលព្រៃទៅដល់ថៃ ទៅដល់អី ។ ដេញៗ ទៅដល់ថៃ ។

វីណា៖ ចុះអត់មានខ្មែរក្រហមដូចថាពេលវៀតណាមចូលម៉ោអត់រត់ទៅតាម?

ស៊ីន៖ មានខ្លះដូចថាទ័ពវៀតណាមដេញទៅ វាដាច់ខ្សែរយៈទាក់ទង ដល់អញ្ចឹងទៅ នៅតាមព្រៃ ខ្លះ បន្កប់ខ្លួន បួនដប់នាក់ចឹងទៅណាស់ ។ ដល់វៀតណាមឡើងទៀតទៅ ខ្លះចេញម៉ោ ធ្វើសកម្មភាពនៅក្នុងភូមិ ។

វីណា៖ នៅតែធ្វើខ្មែរក្រហម?

ស៊ីន៖ បាទ នៅតែធ្វើខ្មែរក្រហមចឹង ។ វាមិនទាន់ម៉ោចូលម៉ោសម្លាប់ចូលម៉ោបាញ់អីទេ វាគ្រាន់តែនេះ ចូលម៉ោវាសុំអីសុំនោះស៊ីណាស់ ។ អន្តរបាយចឹងទៅ វាដាច់ណាស់ ។

វីណា៖ ចុះពូម៉េចក៏ត្រូវរត់ទៅនោះ?

ស៊ីន៖ យើងមិនហ៊ាននៅទេ វៀតណាមឡើងម៉ោ ។ វានៅ ដេរូចដូរាច ដូចខ្ញុំនិយាយមិញចឹង ។ វានៅបន្កប់ណោះបួនដប់នាក់ នៅណោះបួនប្រាំនាក់ ។ ខ្លាចអាពួកហ្នឹងវាសម្លាប់យើងណាស់ ។ ដល់អញ្ចឹងទៅ យើងនៅណោះសិន ។ ដល់មើលស្ងប់ ថាវាធូរស្រាលហើយ ពួកហ្នឹងវាឡើងទៅនោះអស់ បានហ៊ានម៉ោនៅនេះ ។

វីណា៖ ចុះពូថាមានកន្លែងខ្លះត្រូវគេសម្លាប់ពេល៧៩ហ្នឹង?

ស៊ីន៖ បាទ ហ្នឹងហើយពេល៧៩ហ្នឹងហើយ ។ ដល់ក្រោយវៀតណាមឡើងហួសទៅ ទាល់ស្ងប់ស្ងាត់ទៅ ឡើងម៉ោនៅគ្រប់គ្នាវិញអ្ហាស៎ ។ តាមភូមិចឹងទៅ ដល់ពេលហ្នឹងហើយឆ្មៀត ហ្នឹងឯង ។

វីណា៖ ឆ្មៀត?

ស៊ីន៖ បាទ ឆ្មៀត ។ ឆ្មៀតអាពេលហ្នឹងឯង អ្នកដែលទំនាស់ៗវាសម្លាប់គ្នាហ្នឹងអ្ហាស៎ ។ អ្នកដែលមេកងៗម៉ោនៅភូមិអីវិញចឹងទៅ អ្នកដែលគេខឹង គេលួចសម្លាប់ចឹងទៅ ។

វីណា៖ ចឹងខ្មែរក្រហមដែលនៅក្នុងព្រៃហ្នឹង គេមានធ្វើសកម្មភាពអីទៀតអ្ហ៎?

ស៊ីន៖ គេឡើងទៅ វានៅបន្ទាត់ពនៅព្រំដែនណោះ! ហើយនៅខាងក្នុងនេះវាមិនទាន់ធ្វើ សកម្មភាពទេដល់ក្រោយម៉ោទៀត ប៉ែតពីរប៉ែតបីបានចុះម៉ោធ្វើសកម្មភាពវិញ ។

វីណា៖ ចុះម៉ោធ្វើអីខ្លះពូ?

ស៊ីន៖ គេចុះម៉ោធ្វើសកម្មភាពតាមភូមិទៅ គេចូលម៉ោឃោសនាអញ្ចេះអញ្ចេះទៅ ។ វាបាញ់ ជាមួយទ័ពវៀតណាមអីចឹងទៅណាស់ ។

ទ័ពវៀតណាមមាននៅក្នុងផងនៅក្រៅទៀត ។ បើវាចេញម៉ោពីក្រៅម៉ោ ។ វៀតណាមនៅលើណាស់ ប៉ុនវាឆ្មៀតចេញម៉ោបាន វាចូលម៉ោក្នុងនេះវិញ ។ ចឹងវាលួនម៉ោធ្វើសកម្មភាពបាញ់ទ័ពយើងនៅក្នុងខ្លះ វៀតណាមខ្លះទៅ ។ ប៉ុនវាច្របូកច្របល់សម័យប៉ែតពីរប៉ែតបីឡើងទៅណាស់ ។

វីណា៖ ចុះដល់ពេលណាបានស្ងប់វិញទៅ?

ស៊ីន៖ ទាល់ដល់៩៣ ។

វីណា៖ ចឹងបានន័យថាកន្លែងនេះនៅតែប្រទាញប្រទង់គ្នា?

ស៊ីន៖ កន្លែងនេះដូចកន្លែងតំបន់សមរភូមិ ។ ប៉ែតពីរប៉ែតបី ប៉ែតប្រាំប៉ែតប្រាំមួយ ពីមុខនេះ គ្មានផ្ទះទេក្មួយ ។

វីណា៖ ចាស ។

ស៊ីន៖ គ្មានផ្ទះទេ ប្រជាជនក៏គ្មានដែរ ។ មានត្រឹមណោះទៅណោះទេ ។ នេះឡើងទៅសុទ្ធព្រៃ ក្មួយអឺយ! មិនចង់ហ៊ានដើរផង ។ ភូមិនោះខ្មែរក្រហម ប៉ុរ៉ាគេចុះម៉ោធ្វើសកម្មភាព អ្ហាស់ក្មួយ ។ គេម៉ោគេមានចាប់អ្នកធ្វើការមួយៗសម្លាប់ចោលទៅ ។ ជួនកាលគេកៀរ អ្នកដែលប្រជាជននោះណាស់ ។ ដល់សម័យប៉ែតបីប៉ែតបួនហើយ វាមានឆ្មៀតម៉ោធ្វើ សកម្មភាព កៀរយកប្រជាជនទៅទៀតណាស់ ។ ធ្វើទ័ពធ្វើទាញជាមួយវាទៀត ។

វីណា៖ ពូធ្វើអីដែរកាលហ្នឹង?

ស៊ីនៈ ខ្ញុំ៧៩ម៉ោ ខ្ញុំធ្វើនគរបាលភូមិ ។ នគរបាលភូមិរហូតដល់ឆ្នាំ៩៣ ។ ទាល់ដល់៩៣បានខ្ញុំធ្វើអនុប្រធានភូមិវិញ ។

វីណាៈ ធ្វើនគរបាលភូមិហ្នឹងគេរើស ឬក៏ពូស្ម័គ្រចិត្តចូល?

ស៊ីនៈ កាលហ្នឹងខាងស្រុកគាត់រើសអ្ហាស់! អត់មានបោះឆ្នោតអីទេ ។ ដូចថាខ្ញុំនៅភូមិនេះទៅគាត់រើសខ្ញុំមួយទៅណាស់ ។ ដល់២០០៦ ទើបបោះឆ្នោតខ្ញុំជាប់ជាមេភូមិនេះ ។

វីណាៈ អញ្ចឹង អរគុណពូច្រើន ។